# ក្រុមហ៊ុន អន្តរ មីក្រូហិរញ្ញវត្ថុ (កម្ពុជា) ខូ អិលធីឌី

## របាយការណ៍ហិរញ្ញវត្ថុ
## សម្រាប់ការិយបរិច្ឆេទដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១១

**ក្រុមហ៊ុន អង្គរ មីក្រូហិរញ្ញវត្ថុ (កម្ពុជា) ខូ អិលធីឌី**

**របាយការណ៍ហិរញ្ញវត្ថុ**
**សម្រាប់ដំណាច់ការិយបរិច្ឆេទឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១១**

| **មាតិកា** | **ទំព័រ** |
|---|---|
| របាយការណ៍ក្រុមប្រឹក្សាភិបាល | ១ - ៤ |
| របាយការណ៍សវនករឯករាជ | ៥ - ៦ |
| តារាងតុល្យការ | ៧ |
| របាយការណ៍លទ្ធផល | ៨ |
| របាយការណ៍បម្រែបម្រួលមូលធន | ៩ |
| របាយការណ៍ចលនាសាច់ប្រាក់ | ១០ |
| កំណត់សម្គាល់ របាយការណ៍ហិរញ្ញវត្ថុ | ១១ - ៧៦ |
| ឧបសម្ព័ន្ធ : កំណត់សម្គាល់ស្តីពីការអនុវត្តតាមប្រកាសរបស់ធនាគារកណ្តាល* | i – ix |

* ឧបសម្ព័ន្ធនេះ មិនមែនជាផ្នែកនៃរបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មនេះទេ។

អាគារលេខ៤៤២ ផ្លូវ១៩៣ សង្កាត់ទួលស្វាយព្រៃ១ ខណ្ឌចំការមន រាជធានីភ្នំពេញ
ប្រអប់សំបុត្រ ៤៨០ ▪ ទូរស័ព្ទលេខ: (៨៥៥) ២៣ ៩៩៣ ០៦២ ▪ ទូរសារលេខ: (៨៥៥) ២៣ ២២១ ៦៥០
Angkor Mikroheranhvatho (Kampuchea) Co., Ltd
No.442, St.193, Sk.Tuolsvayprey1, Kh.Chamkarmorn, Phnom Penh, Cambodia
P.O Box 480 ▪ Tel: (855) 23 993 062 ▪ Fax: (855) 23 221 650
www.amkcambodia.com ▪ email: info@amkcambodia.com


## របាយការណ៍ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុន អង្គរ មីក្រូហិរញ្ញវត្ថុ (កម្ពុជា) ខូ អិលធីឌី (ហៅកាត់ថា "ក្រុមហ៊ុន") មានសេចក្តីសោមនស្ស សូមដាក់ជូនរបាយការណ៍របស់ខ្លួន និងរបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរួច សម្រាប់ការិយបរិច្ឆេទដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១១។

## សកម្មភាពចម្បង

សកម្មភាពចម្បងរបស់ ក្រុមហ៊ុន អង្គរ មីក្រូហិរញ្ញវត្ថុ (កម្ពុជា) ខូ អិលធីឌី គឺផ្តល់សេវាកម្មមីក្រូហិរញ្ញវត្ថុជូនប្រជាពលរដ្ឋក្រីក្រកម្ពុជា តាមរយៈការិយាល័យកណ្តាលរបស់ខ្លួននៅរាជធានីភ្នំពេញ និងតាមរយៈបណ្តាសាខាជាច្រើនទៀត នៅរាជធានីភ្នំពេញ និងបណ្តាខេត្តនានា នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

## លទ្ធផលហិរញ្ញវត្ថុ

លទ្ធផលហិរញ្ញវត្ថុសម្រាប់ការិយបរិច្ឆេទដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១១ ត្រូវបានបង្ហាញក្នុងរបាយការណ៍លទ្ធផល នៅលើទំព័រទី ៨ នៃរបាយការណ៍ហិរញ្ញវត្ថុ។

## ទ្រព្យសកម្ម

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីកាលៈទេសៈណាមួយ ដែលបណ្តាលអោយតម្លៃទ្រព្យសកម្ម នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន មានកំហុសឆ្គងនោះទេ។

## ទ្រព្យអកម្មយថាភាព និងទ្រព្យអកម្មផ្សេងៗ

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ មិនមាន :

ក. បន្ទុកណាមួយលើទ្រព្យសកម្មរបស់ក្រុមហ៊ុន ដែលបានកើតឡើងចាប់តាំងពីដំណាច់ឆ្នាំ សម្រាប់ការធានាបំណុលរបស់បុគ្គលណាមួយ ឬ

ខ. ទ្រព្យអកម្មយថាភាពណាមួយរបស់ក្រុមហ៊ុន ដែលបានកើតឡើងចាប់ពីដំណាច់ឆ្នាំមក។

តាមយោបល់របស់ក្រុមប្រឹក្សាភិបាល មិនមានទ្រព្យអកម្មយថាភាព ឬទ្រព្យអកម្មផ្សេងៗរបស់ក្រុមហ៊ុន ដែលត្រូវបានទាមទារអោយសង ឬអាចនឹងត្រូវទាមទារអោយសង ក្នុងរយៈពេល១២ខែ គិតចាប់ពីដំណាច់ឆ្នាំ ដែលនឹង ឬអាចនឹងមានឥទ្ធិពលយ៉ាងធ្ងន់ធ្ងរដល់លទ្ធភាពរបស់ក្រុមហ៊ុនក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួន នៅថ្ងៃកំណត់សងនោះទេ។

## ការផ្លាស់ប្តូរកាលៈទេសៈ

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលមិនបានដឹងពីកាលៈទេសៈណាមួយ ដែលមិនបានរ៉ែកញែកនៅក្នុងរបាយការណ៍នេះ ឬរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ដែលអាចបណ្តាលអោយចំនួនទឹកប្រាក់ដែលបានបង្ហាញក្នុងរបាយការណ៍ហិរញ្ញវត្ថុមានកំហុសឆ្គងនោះទេ។

## ប្រតិបត្តិការមិនធម្មតា

តាមយោបល់របស់ក្រុមប្រឹក្សាភិបាល លទ្ធផលហិរញ្ញវត្ថុរបស់ក្រុមហ៊ុន សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១១ ពុំមានរងនូវការប៉ះពាល់ជាសារវន្តពីគណនី ប្រតិបត្តិការ ឬព្រឹត្តិការណ៍ណាមួយ ដែលមានលក្ខណៈជាសារវន្ត និងមិនធម្មតានោះទេ។

តាមយោបល់របស់ក្រុមប្រឹក្សាភិបាល មិនមានគណនី ប្រតិបត្តិការ ឬព្រឹត្តិការណ៍ណាមួយ ដែលមានលក្ខណៈជាសារវន្ត និងមិនធម្មតា ដែលបានកើតឡើងនៅក្នុងចន្លោះពេលរវាងថ្ងៃបិទបញ្ជី និងកាលបរិច្ឆេទនៃរបាយការណ៍នេះ ដែលអាចនាំអោយប៉ះពាល់ជាសារវន្ត លើលទ្ធផលប្រតិបត្តិការរបស់ក្រុមហ៊ុន ក្នុងឆ្នាំនេះទេ។

## ព្រឹត្តិការណ៍សំខាន់ៗ

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ មិនមានព្រឹត្តិការណ៍ដែលមានលក្ខណៈជាសារវន្តណាមួយ បានកើតឡើង ក្រោយកាលបរិច្ឆេទតារាងតុល្យការ ដែលតម្រូវអោយមាននិយ័តកម្ម ឬការលាតត្រដាងណាមួយ ក្រៅពីការលាតត្រដាងផ្សេងៗ ក្នុងរបាយការណ៍ហិរញ្ញវត្ថុនេះទេ។

## ក្រុមប្រឹក្សាភិបាល

សមាជិកក្រុមប្រឹក្សាភិបាលក្នុងអំឡុងឆ្នាំ និងគិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ មានរាយនាមដូចខាងក្រោម:

- លោក Tanmay Chetan ប្រធានក្រុមប្រឹក្សាភិបាល
- លោក Peter Power សមាជិកក្រុមប្រឹក្សាភិបាល និងជានាយកប្រតិបត្តិ
- លោក Howard Dalzell សមាជិកក្រុមប្រឹក្សាភិបាល
- លោកស្រី Frances Sinha សមាជិកក្រុមប្រឹក្សាភិបាល

- លោក Tip Janvibol សមាជិកក្រុមប្រឹក្សាភិបាល
- លោកស្រី Rebecca McKenzie សមាជិកក្រុមប្រឹក្សាភិបាល
- លោក Marcus Fedder សមាជិកក្រុមប្រឹក្សាភិបាល
- លោកស្រី Irina Ignatieva សមាជិកក្រុមប្រឹក្សាភិបាល
- លោក Adrian Graham សមាជិកក្រុមប្រឹក្សាភិបាល

## ផលកម្រៃរបស់ក្រុមប្រឹក្សាភិបាល

ពុំមានសមាជិកក្រុមប្រឹក្សាភិបាលណាម្នាក់ កាន់កាប់ផលកម្រៃ ក្នុងមូលធនរបស់ក្រុមហ៊ុននោះទេ។ ក្រុមហ៊ុនមិនបានចូលរួមក្នុងការរៀបចំណាមួយ ក្នុងគោលបំណងជួយដល់សមាជិកក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុន ដើម្បីអោយទទួលបានផលកម្រៃតាមរយៈការទិញភាគហ៊ុន ឬប័ណ្ណបំណុលពីសាម៉ីក្រុមហ៊ុន ឬក្រុមហ៊ុនផ្សេងទៀតឡើយ ។

## អត្ថប្រយោជន៍របស់ក្រុមប្រឹក្សាភិបាល

ក្នុងអំឡុងឆ្នាំ និងគិតត្រឹមដំណាច់ឆ្នាំនេះ ក្រុមហ៊ុនមិនបានចូលរួមក្នុងការរៀបចំណាមួយ ក្នុងគោលបំណងជួយដល់សមាជិកក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុន ដើម្បីអោយទទួលបានអត្ថប្រយោជន៍ តាមរយៈការទិញភាគហ៊ុន ឬប័ណ្ណបំណុល ពីសាម៉ីក្រុមហ៊ុន ឬក្រុមហ៊ុនផ្សេងទៀតឡើយ ។

មិនមានសមាជិកក្រុមប្រឹក្សាភិបាលណាម្នាក់របស់ក្រុមហ៊ុនទទួលបាន ឬមានសិទ្ធិនឹងទទួលបាននូវអត្ថប្រយោជន៍ណាមួយ (ក្រៅពីអត្ថប្រយោជន៍ផ្សេងៗ ដែលបានរួមបញ្ចូលទៅក្នុងចំនួនអត្ថប្រយោជន៍សរុប ដែលសមាជិកក្រុមប្រឹក្សាភិបាលម្នាក់ៗត្រូវទទួលបាន ដូចបានលាតត្រដាងនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ) តាមរយៈការចុះកិច្ចសន្យាដែលបានធ្វើឡើង រវាងក្រុមហ៊ុន ឬរវាងក្រុមហ៊ុនដែលក្រុមប្រឹក្សាភិបាលនោះជាសមាជិក ឬជាមួយក្រុមហ៊ុនដែលសមាជិកក្រុមប្រឹក្សាភិបាលនោះ មានផលប្រយោជន៍ផ្នែកហិរញ្ញវត្ថុជាសារវន្ត ក្រៅពីអ្វីដែលបានលាតត្រដាង នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុនេះទេ។

## ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាល ចំពោះរបាយការណ៍ហិរញ្ញវត្ថុ

ក្រុមប្រឹក្សាភិបាល ទទួលខុសត្រូវក្នុងការបញ្ជាក់ថា របាយការណ៍ហិរញ្ញវត្ថុ ត្រូវបានរៀបចំឡើងយ៉ាងត្រឹមត្រូវ ដោយផ្តល់នូវទិដ្ឋភាពពិត និងត្រឹមត្រូវ អំពីស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុន គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១១ និងលទ្ធផលហិរញ្ញវត្ថុ ព្រមទាំងចលនាសាច់ប្រាក់សម្រាប់ដំណាច់ឆ្នាំ។ ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុនេះ តម្រូវអោយក្រុមប្រឹក្សាភិបាល :

១. ជ្រើសរើសគោលការណ៍គណនេយ្យដែលសមស្របមកប្រើ ដែលគាំទ្រដោយការវិនិច្ឆ័យ និងការប៉ាន់ប្រមាណយ៉ាងសមហេតុផល និងប្រកបដោយការប្រុងប្រយ័ត្ន ហើយបន្ទាប់មក ត្រូវអនុវត្តអោយមានភាពស៊ីសង្វាក់គ្នា ។

២. អនុវត្តតាមតំរូវការក្នុងការលាតត្រដាងព័ត៌មាន និងគោលការណ៍ណែនាំរបស់ធនាគារជាតិ នៃកម្ពុជា និងស្តង់ដារគណនេយ្យកម្ពុជា ឬប្រសិនបើមានការប្រាសចាក ណាមួយពីស្តង់ដារទាំងនោះ ក្នុងការបង្ហាញអោយមានភាពពិត និងត្រឹមត្រូវ ក្រុមប្រឹក្សាភិបាលត្រូវប្រាកដថា ការប្រាសចាកទាំងនេះ ត្រូវបានលាតត្រដាង ពន្យល់ និងកំណត់បរិមាណ អោយបានត្រឹមត្រូវនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

៣. ថែរក្សាកំណត់ត្រាគណនេយ្យអោយបានគ្រប់គ្រាន់ និងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងអោយមានប្រសិទ្ធភាព។

៤. រៀបចំរបាយការណ៍ហិរញ្ញវត្ថុដោយផ្អែកលើមូលដ្ឋាននិរន្តភាពនៃដំណើរការអាជីវកម្ម លុះត្រាតែមានករណីសន្មតដោយសមរម្យថា ក្រុមហ៊ុននឹងមិនអាចបន្តប្រតិបត្តិការអាជីវកម្មនៅពេលអនាគតដ៏ខ្លី និង

៥. ត្រួតពិនិត្យ និងដឹកនាំក្រុមហ៊ុនអោយមានប្រសិទ្ធភាព ដោយចូលរួមលើរាល់ការសំរេចចិត្តសំខាន់ៗទាំងអស់ដែលមានឥទ្ធិពលលើប្រតិបត្តិការ និងលទ្ធផលអាជីវកម្មរបស់ក្រុមហ៊ុន ហើយត្រូវប្រាកដថាកិច្ចការទាំងនេះ ត្រូវបានឆ្លុះបញ្ចាំងយ៉ាងត្រឹមត្រូវ នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

ក្រុមប្រឹក្សាភិបាលអះអាងថា ក្រុមហ៊ុនបានអនុវត្តតាមការតំរូវខាងលើ ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ។

## របាយការណ៍ក្រុមប្រឹក្សាភិបាល

តាងនាមក្រុមប្រឹក្សាភិបាលក្រុមហ៊ុន អង្គរ មីក្រូហិរញ្ញវត្ថុ (កម្ពុជា) ខូ អិលធីឌី យើងខ្ញុំសូមធ្វើការបញ្ជាក់អះអាងថា របាយការណ៍ហិរញ្ញវត្ថុ ព្រមទាំងកំណត់សំគាល់ទាំងឡាយដែលបានភ្ជាប់មកជាមួយនេះ បានបង្ហាញយ៉ាងត្រឹមត្រូវ នូវគ្រប់ទិដ្ឋភាពជាសារវន្តទាំងអស់ នៃស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុន គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១១ ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងលំហូរសាច់ប្រាក់ សំរាប់ដំណាច់ឆ្នាំ ដោយអនុលោមតាមស្តង់ដារគណនេយ្យកម្ពុជា និងគោលការណ៍ណែនាំរបស់ធនាគារជាតិ នៃកម្ពុជា ក្នុងការរៀបចំ និងការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុនេះ។

ជ. ក្រុមប្រឹក្សាភិបាល

លោក Tanmay Chetan

ប្រធានក្រុមប្រឹក្សាភិបាល

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

កាលបរិច្ឆេទ: 21 MAR 2012

PRICEWATERHOUSECOOPERS

**PricewaterhouseCoopers (Cambodia) Ltd.**
35, Sihanouk Boulevard, Chamkarmon
Phnom Penh, Kingdom of Cambodia
Telephone (855) 23 218 086
Facsimile (855) 23 211 594

## របាយការណ៍សវនករឯករាជ

ជូនភាគទុនិក ក្រុមហ៊ុន អង្គរ មីក្រូហិរញ្ញវត្ថុ (កម្ពុជា) ខូ អិលធីឌី

យើងខ្ញុំបានធ្វើសវនកម្មទៅលើរបាយការណ៍ហិរញ្ញវត្ថុ របស់ក្រុមហ៊ុន អង្គរ មីក្រូហិរញ្ញវត្ថុ (កម្ពុជា) ខូ អិលធីឌី (ហៅកាត់ថា "ក្រុមហ៊ុន") រួមមានតារាងតុល្យការ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១១ របាយការណ៍លទ្ធផល របាយការណ៍បម្រែបម្រួលមូលធន និងរបាយការណ៍ចលនាសាច់ប្រាក់សម្រាប់ដំណាច់ឆ្នាំ ព្រមទាំងសេចក្តីសង្ខេបនៃគោលការណ៍ គណនេយ្យសំខាន់ៗ និងកំណត់សម្គាល់ផ្សេងៗទៀត ។

## ការទទួលខុសត្រូវរបស់គណៈគ្រប់គ្រងលើរបាយការណ៍ហិរញ្ញវត្ថុ

គណៈគ្រប់គ្រង ទទួលខុសត្រូវក្នុងការរៀបចំ និងការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុទាំងនេះអោយបានត្រឹមត្រូវ ដោយអនុលោមទៅតាមគោលការណ៍ណែនាំផ្សេងៗ របស់ធនាគារជាតិ នៃកម្ពុជា និងស្តង់ដារគណនេយ្យកម្ពុជា និងទទួលខុសត្រូវលើការត្រួតពិនិត្យផ្ទៃក្នុង ដែលគណៈគ្រប់គ្រងកំណត់ថា វាមានភាពចាំបាច់ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ មិនអោយមានការរាយការណ៍ខុសជាសារវន្ត ដែលបណ្តាលមកពីការក្លែងបន្លំ ឬកំហុសឆ្គងផ្សេងៗ ។

## ការទទួលខុសត្រូវរបស់សវនករ

ការទទួលខុសត្រូវរបស់យើងខ្ញុំ គឺបញ្ចេញមតិលើរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ ដោយផ្អែកទៅលើការធ្វើសវនកម្មរបស់យើងខ្ញុំ។ យើងខ្ញុំ បានធ្វើសវនកម្មដោយអនុលោមទៅតាមស្តង់ដារសវនកម្មអន្តរជាតិ នៃកម្ពុជា។ ស្តង់ដារទាំងនោះ តម្រូវអោយយើងខ្ញុំប្រតិបត្តិតាមក្រមសីលធម៌ ធ្វើផែនការ និងធ្វើសវនកម្ម ដើម្បីទទួលបាននូវការធានាអះអាង ដែលសមហេតុផលថា របាយការណ៍ហិរញ្ញវត្ថុពុំមានលក្ខណៈខុសឆ្គងជាសារវន្ត។

PRICEWATERHOUSECOOPERS

ការធ្វើសវនកម្ម រួមមានការអនុវត្តនីតិវិធីដើម្បីទទួលបាននូវភស្តុតាងសវនកម្ម អំពីចំនួនទឹកប្រាក់ និងការដាក់បង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។ ការជ្រើសរើសនីតិវិធីទាំងនេះ គឺអាស្រ័យលើការវិនិច្ឆ័យរបស់សវនករ ដោយរួមបញ្ចូលទាំងការវាយតម្លៃលើហានិភ័យនៃភាពខុសឆ្គងជាសារវន្ត នៃរបាយការណ៍ហិរញ្ញវត្ថុ ដែលបណ្តាលមកពីការក្លែងបន្លំ ឬកំហុសឆ្គង។ ក្នុងការវាយតម្លៃហានិភ័យទាំងនោះ សវនករបានពិចារណាទៅលើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងរបស់ក្រុមហ៊ុនដែលទាក់ទងទៅនឹងការរៀបចំ និងការបង្ហាញយ៉ាងត្រឹមត្រូវនៃរបាយការណ៍ហិរញ្ញវត្ថុ ដើម្បីរៀបចំនូវនីតិវិធីសវនកម្មដែលមានលក្ខណៈសមហេតុផលទៅតាមកាលៈទេសៈផ្សេងៗ ប៉ុន្តែការពិចារណានេះ ពុំមានគោលបំណងបញ្ចេញមតិទៅលើប្រសិទ្ធភាពនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងរបស់ក្រុមហ៊ុននោះទេ។ សវនកម្មក៏រួមបញ្ចូលទាំងការវាយតម្លៃនូវភាពសមស្របនៃគោលការណ៍គណនេយ្យដែលបានប្រើប្រាស់ និងភាពសមហេតុផលនៃការប៉ាន់ស្មានគណនេយ្យ ដែលធ្វើឡើងដោយគណៈគ្រប់គ្រង ក៏ដូចជាការវាយតម្លៃលើការបង្ហាញជាទូទៅនៃរបាយការណ៍ហិរញ្ញវត្ថុ។

យើងខ្ញុំ ជឿជាក់ថាភស្តុតាងសវនកម្មដែលយើងទទួលបាន គឺមានលក្ខណៈគ្រប់គ្រាន់ និងត្រឹមត្រូវ ដែលជាមូលដ្ឋានសម្រាប់ការបញ្ចេញមតិយោបល់របស់យើងខ្ញុំ ។

**មតិយោបល់**

តាមទស្សនៈរបស់យើងខ្ញុំ របាយការណ៍ហិរញ្ញវត្ថុ បានបង្ហាញត្រឹមត្រូវនូវគ្រប់ទិដ្ឋភាពជាសារវន្តទាំងអស់ នៃស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុន គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១១ និងលទ្ធផលហិរញ្ញវត្ថុ ព្រមទាំងចលនាសាច់ប្រាក់សម្រាប់ដំណាច់ឆ្នាំ ដោយអនុលោមទៅតាមគោលការណ៍ណែនាំរបស់ធនាគារជាតិ នៃកម្ពុជា និង ស្តង់ដារគណនេយ្យកម្ពុជា។

ជ. PricewaterhouseCoopers (Cambodia) Ltd.

**គុយ លីម**

**នាយក**

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

កាលបរិច្ឆេទ : ថ្ងៃទី២១ ខែមីនា ឆ្នាំ២០១២

## ក្រុមហ៊ុន អេក្ខារ មីក្រូហិរញ្ញវត្ថុ (កម្ពុជា) ខូ អិលធីឌី
## តារាងតុល្យការ
## គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១១

| | កំណត់ សម្គាល់ | ២០១១ ពាន់រៀល | ២០១១ ដុល្លារអាមេរិក | ២០១០ ពាន់រៀល | ២០១០ ដុល្លារអាមេរិក |
|---|---|---|---|---|---|
| **ទ្រព្យសកម្ម** | | | | | |
| សាច់ប្រាក់ក្នុងដៃ | ៤ | ១.៥២០.៤០៤ | ៣៧៦.៤៣១ | ៨៣០.៥២៧ | ២០៤.៩១៧ |
| សមតុល្យនៅធនាគារកណ្តាល | ៥ | ៤.៨៥៥.៣៤៣ | ១.២០២.១១៥ | ៥.២១៥.០៣១ | ១.២៨៦.៧០៩ |
| សមតុល្យនៅធនាគារផ្សេងៗ | ៦ | ៦៦.១២៥.៥៤៥ | ១៦.៣៧១.៧៦២ | ៣៥.៩៦៨.១៩៨ | ៨.៨៧៤.៤៦៣ |
| ឥណទានអតិថិជន | ៧ | ១៩០.០៨៨.៨២២ | ៤៧.០៦៣.៣៣៨ | ១២៩.៩៩៨.៨៣៣ | ៣០.៩៨៩.១០៣ |
| ទ្រព្យសកម្មផ្សេងៗ | ៨ | ៦.៦៦៦.៧៤០ | ១.៦៥០.៥៩២ | ៣.៨៧១.៣៩៨ | ៩៥៥.១៨៣ |
| ទ្រព្យសម្បត្តិ និងបរិក្ខារ | ៩ | ៤.៣៥០.៩៤៥ | ១.០៧៧.២៣៣ | ៣.៨១៤.១១៨ | ៩៤១.០៦០ |
| ទ្រព្យសកម្មអរូបី | ១០ | ១.៨៥៦.៩៧៦ | ៤៥៩.៦៦២ | ២.៣៧៨.០០៤ | ៥៨៦.៧២៧ |
| ពន្ធពន្យារជាទ្រព្យសកម្ម | ១១ | ៧៩៣.៤៦៩ | ១៩៦.៤៥២ | ២៤២.១៨៦ | ៥៩.៧៥៥ |
| **ទ្រព្យសកម្មសរុប** | | ២៧៦.២៩៧.៨៤៤ | ៦៨.៣៩៧.៩៨៥ | ១៧៧.៩១៨.២៩៩ | ៤៣.៨៩៧.៩១៧ |
| **ទ្រព្យអកម្ម** | | | | | |
| ប្រាក់បញ្ញើរបស់អតិថិជន | ១២ | ១៨.៩៣៤.១០២ | ៤.៩៨៨.៧៨៥ | ៥.៧៨១.៧៣១ | ១.៤២៦.៩៣១ |
| ប្រាក់ជំពាក់ភាគទុនិក | | - | - | ៧៦.៦៦៤ | ១៨.៩១៧ |
| ពន្ធទ្រព្យអកម្ម | ១៣ | ១.៨៥៦.៤១៧ | ៤៥៩.៦២៣ | ៤៣០.៨៦២ | ១០៦.៣០៧ |
| ទ្រព្យអកម្មផ្សេងៗ | ១៤ | ៨.១១៤.២៤០ | ២.០០៨.៩៧៣ | ៣.៩៧០.១៩៤ | ៩៧៩.៥៦៩ |
| ប្រាក់កម្ចី | ១៥ | ១៨៨.៩១១.៩០៨ | ៤៦.៦៧២.៩១៦ | ១១៧.១៧៩.៤១៧ | ២៨.៩១១.៧៧៣ |
| សំវិធានធនសម្រាប់មូលនិធិសោធននិវត្តន៍ របស់បុគ្គលិក | ១៦ | ៣.០១១.២៨១ | ៧៤៥.៥៥១ | ២.០៣៩.៣០៥ | ៥០៣.១៥៩ |
| **ទ្រព្យអកម្មសរុប** | | ២២០.០២៧.៩៤៨ | ៥៤.៤៧៥.៨៤៨ | ១២៩.៤៧៨.១៧៣ | ៣១.៩៤៦.២៥៦ |
| **មូលធន** | | | | | |
| ដើមទុន | ១៧ | ៣៤.៥៧៩.២០០ | ៨.៥៦១.៣២៧ | ៣៤.០៦៩.២៥០ | ៨.៤០៥.៩៣៤ |
| បុព្វលាភភាគហ៊ុន | | ៩៥.៥០៦ | ២៣.៦៤៦ | | |
| ដើមទុនបម្រុង | ១៨ | ៣.៣០៤.៣៣៨ | ៨១៨.១០៨ | ១.៥៩០.៦១៨ | ៣៩២.៥៨៥ |
| ចំណេញរក្សាទុក | | ១៨.២៥០.៨៥២ | ៤.៤៦៧.៣១៩ | ១២.៨២០.២១៤ | ៣.១៣១.៦៩៧ |
| លំអៀងពីការប្តូររូបិយប័ណ្ណ | | - | ៥១.៣៣៧ | - | ៣១.៤៤៥ |
| **មូលធនសរុប** | | ៥៦.២២៩.៨៩៦ | ១៣.៩២១.៧៣៧ | ៤៨.៤៤០.០៨២ | ១១.៩៥១.៦៦១ |
| **ទ្រព្យអកម្ម និងមូលធនសរុប** | | ២៧៦.២៩៧.៨៤៤ | ៦៨.៣៩៧.៩៨៥ | ១៧៧.៩១៨.២៩៩ | ៤៣.៨៩៧.៩១៧ |

កំណត់សម្គាល់ដែលភ្ជាប់មកជាមួយពីទំព័រទី ១១ ដល់ទំព័រទី ៧៦ ជាផ្នែកនៃរបាយការណ៍ហិរញ្ញវត្ថុនេះ ។

## ក្រុមហ៊ុន អង្គរ មីក្រូហិរញ្ញវត្ថុ (កម្ពុជា) ខូ អិលធីឌី
## របាយការណ៍លទ្ធផល
## សម្រាប់ការិយបរិច្ឆេទដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១១

| | កំណត់ | ២០១១ | | ២០១០ | |
|---|---|---|---|---|---|
| | សម្គាល់ | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក |
| ចំណូលពីការប្រាក់ | ១៩ | ៥៦.៧៣០.០១០ | ១៣.៩៥២.២៩០ | ៤២.៨១៤.៧៥២ | ១០.២២៣.១៩៨ |
| ចំណាយលើការប្រាក់ | ២០ | (១៦.៣៨៦.៤៣៦) | (៤.០៣០.១១២) | (១២.១១៨.១៩៨) | (២.៨៩៣.៥៥៣) |
| ចំណូលពីការប្រាក់សុទ្ធ | | ៤០.៣៤៣.៥៧៤ | ៩.៩២២.១៧៨ | ៣០.៦៩៦.៥៥៤ | ៧.៣២៩.៦៤៥ |
| ចំណាយកម្រៃ និងកម្រៃជើងសារ | | (៣.០៦០.៥៦០) | (៧៥២.៧២០) | (២.០៨៩.៣៨១) | (៤៩៨.៨៩៧) |
| ចំណូលប្រតិបត្តិការផ្សេងៗ | ២១ | ១.៤៤០.៦៣៦ | ៣៥៤.៣១៣ | ១.៥១៨.៩៨១ | ៣៦២.៦៩៨ |
| ចំណាយប្រតិបត្តិការផ្សេងៗ | ២២ | (២៨.១៧៦.១១០) | (៦.៩២៩.៦៨៨) | (២៣.៩៦០.៦៥៩) | (៥.៧២១.២៧៤) |
| សវិធានធនសម្រាប់ការខាតបង់ឥណទាន ដែលអាចកើតមាន | ៧-ក | (១.៨៨៩.០១៣) | (៤៦៤.៥៨៨) | (១.៦០៣.០៩០) | (៣៨២.៧៨២) |
| ចំណូលប្រតិបត្តិការ | | ៨.៦៥៨.៥២៧ | ២.១២៩.៤៩៥ | ៤.៥៦២.៣៦៥ | ១.០៨៩.៣៩០ |
| ចំណូលជាជំនួយ | ២៣ | ៥១៧.២៩០ | ១២៧.២២៣ | ៦៦៦.៤៣៨ | ១៥៩.១៣០ |
| ចំណេញមុនបង់ពន្ធលើប្រាក់ចំណេញ | | ៩.១៧៥.៨១៧ | ២.២៥៦.៧១៨ | ៥.២២៨.៨០៣ | ១.២៤៨.៥២០ |
| ចំណាយពន្ធលើប្រាក់ចំណេញ | ២៤ | (១.៩៩១.៤៥៩) | (៤៨៩.៧៨៣) | (១.៣១២.០២២) | (៣១៣.២៨១) |
| ចំណេញសុទ្ធក្នុងឆ្នាំ | | ៧.១៨៤.៣៥៨ | ១.៧៦៦.៩៣៥ | ៣.៩១៦.៧៨១ | ៩៣៥.២៣៩ |

កំណត់សម្គាល់ដែលភ្ជាប់មកជាមួយពីទំព័រទី ១១ ដល់ទំព័រទី ៧៦ ជាផ្នែកនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។

# ក្រុមហ៊ុន អន្តរ មីក្រូហិរញ្ញវត្ថុ (កម្ពុជា) ខូ អិលធីឌី
## របាយការណ៍បម្រែបម្រួលមូលធន
## សម្រាប់ការិយបរិច្ឆេទដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១១

| | ដើមទុន | | បុព្វលាភភាគហ៊ុន | | ដើមទុនបម្រុង | | ចំណេញរក្សាទុក | | លំអៀងពីការប្តូររូបិយប័ណ្ណ | សរុប | |
|---|---|---|---|---|---|---|---|---|---|---|---|
| | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក |
| ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១០ | | | | | | | | | | | |
| សមតុល្យនាថ្ងៃទី១ ខែមករា ឆ្នាំ២០១០ | ៣៤.០៦៩.២៥០ | ៨.១៧២.០៤៤ | - | - | - | - | ១០.៤៥៤.០៥១ | ២.៥៦៦.៧១១ | (៥៩.១៤៣) | ៤៤.៥២៣.៣០១ | ១០.៦៧៩.៦១២ |
| ការផ្ទេរទៅដើមទុនបម្រុងក្នុងឆ្នាំ | - | - | - | - | ១.៩៥០.៦១៨ | ៣៧០.២៩៣ | (១.៩៥០.៦១៨) | (៣៧០.២៩៣) | (១២.៣៣២) | - | (១២.៣៣២) |
| ចំណេញសុទ្ធក្នុងឆ្នាំ | - | - | - | - | - | - | ៣.៩១៦.៧៨១ | ៩៣៥.២៣៩ | ៣១.១៥១ | ៣.៩១៦.៧៨១ | ៩៦៦.៣៩០ |
| លំអៀងពីការប្តូររូបិយប័ណ្ណ | - | ២៣៣.៨៩០ | - | - | - | ១២.៣៣២ | - | - | ៧១.៧៦៩ | - | ៣១៧.៩៩១ |
| សមតុល្យនាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១០ | ៣៤.០៦៩.២៥០ | ៨.៤០៥.៩៣៤ | - | - | ១.៩៥០.៦១៨ | ៣៨២.៩៨៥ | ១២.៨២០.២១៤ | ៣.១៣១.៦៩៧ | ៣១.៤៤៥ | ៤៨.៨៤០.០៨២ | ១១.៩៥១.៦៦១ |
| ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១១ | | | | | | | | | | | |
| សមតុល្យនាថ្ងៃទី១ ខែមករា ឆ្នាំ២០១១ | ៣៤.០៦៩.២៥០ | ៨.៤០៥.៩៣៤ | - | - | ១.៩៥០.៦១៨ | ៣៨២.៩៨៥ | ១២.៨២០.២១៤ | ៣.១៣១.៦៩៧ | ៣១.៤៤៥ | ៤៨.៨៤០.០៨២ | ១១.៩៥១.៦៦១ |
| ការបោះផ្សាយភាគហ៊ុនថ្មី | ៥០៩.៩៥០ | ១២៥.៤១៨ | ៩៥.៥០៦ | ២៣.៤៨៩ | - | - | - | - | - | ៦០៥.៤៥៦ | ១៤៨.៩០៧ |
| ការផ្ទេរទៅដើមទុនបម្រុងក្នុងឆ្នាំ | - | - | - | - | ១.៧៥៣.៧២០ | ៤៣១.៣១៣ | (១.៧៥៣.៧២០) | (៤៣១.៣១៣) | - | - | - |
| ចំណេញសុទ្ធក្នុងឆ្នាំ | - | - | - | - | - | - | ៧.១៨៤.៣៥៨ | ១.៧៦៦.៩៣៥ | - | ៧.១៨៤.៣៥៨ | ១.៧៦៦.៩៣៥ |
| លំអៀងពីការប្តូររូបិយប័ណ្ណ | - | ២៩.៩៧៥ | - | ១៥៧ | - | ៤.២១០ | - | - | ១៩.៨៩២ | - | ៥៤.២៣៤ |
| សមតុល្យនាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១១ | ៣៤.៥៧៩.២០០ | ៨.៥៦១.៣២៧ | ៩៥.៥០៦ | ២៣.៦៤៦ | ៣.៣០៤.៣៣៨ | ៨១៨.១០៨ | ១៨.២៥០.៨៥២ | ៤.៤៦៧.៣១៩ | ៥១.៣៣៧ | ៥៦.២២៩.៨៩៦ | ១៣.៩២១.៧៣៧ |

កំណត់សម្គាល់ដែលភ្ជាប់មកជាមួយពីទំព័រទី ១១ ដល់ទំព័រទី ៧៦ ជាផ្នែកនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។

## ក្រុមហ៊ុន អេក្លរ មីក្រូហិរញ្ញវត្ថុ (កម្ពុជា) ខូ អិលធីឌី
## របាយការណ៍ចលនាសាច់ប្រាក់
## សម្រាប់ការិយបរិច្ឆេទដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១១

| | កំណត់ | ២០១១ | | ២០១០ | |
|---|---|---|---|---|---|
| | សម្គាល់ | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក |
| **ចលនាសាច់ប្រាក់ពីសកម្មភាពប្រតិបត្តិការ** | | | | | |
| សាច់ប្រាក់បានប្រើក្នុងប្រតិបត្តិការ | ២៥ | (៦៣.២៦៧.៤៥៥) | (១៥.៥៦០.១២២) | (១៣.១៨៩.៨១១) | (៣.១៤៩.៤៣០) |
| ពន្ធលើប្រាក់ចំណេញបានបង់ | ១៣ | (១.១១៧.១៨៦) | (២៧៤.៧៦៣) | (៩៥១.៤០៨) | (២២៧.១៧៥) |
| មូលនិធិសោធននិវត្តន៍របស់បុគ្គលិកបានបង់ | | (៣០៦.០៣៤) | (៧៥.២៦៧) | (២៤៥.៦៨៦) | (៥៨.៦៦៤) |
| សាច់ប្រាក់សុទ្ធបានប្រើក្នុងសកម្មភាពប្រតិបត្តិការ | | (៦៤.៦៩០.៦៧៥) | (១៥.៩១០.១៥២) | (១៤.៣៨៦.៩០៥) | (៣.៤៣៥.២៦៩) |
| **ចលនាសាច់ប្រាក់ពីសកម្មភាពវិនិយោគ** | | | | | |
| ប្រាក់បញ្ញើដើមទុនដែលមានការធានានៅ | | | | | |
| ធនាគារកណ្តាល | | - | - | (១.៧០៣.៤៦២) | (៤០៦.៧៤៨) |
| ការទិញទ្រព្យសម្បត្តិ និងបរិក្ខារ | ៩ | (១.៨៥២.៣២៩) | (៤៥៥.៥៦៥) | (១.១៨១.២៥៦) | (២៨២.០៦៧) |
| ការទិញទ្រព្យសកម្មអរូបី | ១០ | (២០.៨៧៩) | (៥.១៣៥) | (២.៣៦៤.៧៦២) | (៥៦៤.៦៥២) |
| សាច់ប្រាក់បានពីការលក់ទ្រព្យសម្បត្តិ និងបរិក្ខារ | | ៥០.២៧១ | ១២.៣៦៤ | ១០.១២២ | ២.៤១៧ |
| សាច់ប្រាក់សុទ្ធបានប្រើក្នុងសកម្មភាពវិនិយោគ | | (១.៨២២.៩៣៧) | (៤៤៨.៣៣៦) | (៥.២៣៩.៣៥៨) | (១.២៥១.០៥០) |
| **ចលនាសាច់ប្រាក់ពីសកម្មភាពហិរញ្ញប្បទាន** | | | | | |
| សាច់ប្រាក់បានពីប្រាក់កម្ចី | | ១០១.២៣៩.៣៣៤ | ២៤.៨៩៩.០០០ | ៤៦.៣៣៣.៤៦៩ | ១១.០៦៣.៣៨៨ |
| ការសងប្រាក់កម្ចី | | (៣៣.៩៤៤.០៦១) | (៨.៣៤៨.២៦៩) | (៣៥.៩៧៤.៧៩៧) | (៨.៥៨៩.៩៧១) |
| សាច់ប្រាក់បានពីការបោះផ្សាយភាគហ៊ុន | | ៦០៥.៤៥៦ | ១៤៩.៩០២ | - | - |
| សាច់ប្រាក់សុទ្ធបានពីសកម្មភាពហិរញ្ញប្បទាន | | ៦៧.៩០០.៧២៩ | ១៦.៧០០.៦៣៣ | ១០.៣៥៨.៦៧២ | ២.៤៧៣.៤១៧ |
| **កំណើន/(តំហយ) សុទ្ធ នៃសាច់ប្រាក់** | | | | | |
| **និងសាច់ប្រាក់ សមមូល** | | ១.៣៨៧.១១៧ | ៣៤២.១៤៥ | (៩.២៦៧.៦៣១) | (២.២១២.៩០២) |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូលនាដើមឆ្នាំ | ៤ | ១៩.១១៧.៧៣១ | ៤.៧១៦.៩៣៣ | ២៨.៣៨៥.៣៦២ | ៦.៨០៨.៦៧៤ |
| លំអៀងពីការប្តូររូបិយប័ណ្ណ | | - | ១៧.៦៣៦ | - | ១២១.១៦១ |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូលនាចុងឆ្នាំ** | | ២០.៥០៤.៨៤៨ | ៥.០៧៦.៧១៤ | ១៩.១១៧.៧៣១ | ៤.៧១៦.៩៣៣ |

កំណត់សម្គាល់ដែលភ្ជាប់មកជាមួយពីទំព័រទី ១១ ដល់ទំព័រទី ៧៦ ជាផ្នែកនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។

# ក្រុមហ៊ុន អង្គរ មីក្រូហិរញ្ញវត្ថុ (កម្ពុជា) ខូ អិលធីឌី

## កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ
## សម្រាប់ការិយបរិច្ឆេទដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១១

## ១. ព័ត៌មានទូទៅ

ក្រុមហ៊ុន អង្គរ មីក្រូហិរញ្ញវត្ថុ (កម្ពុជា) ខូ អិលធីឌី (ហៅកាត់ថា "ក្រុមហ៊ុន" ឬ "AMK") គឺជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលទទួលបានអាជ្ញាប័ណ្ណធ្វើអាជីវកម្មនៅប្រទេសកម្ពុជា និងបានចុះបញ្ជីនៅក្រសួងពាណិជ្ជកម្ម ជាក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត ក្រោមបញ្ជីលេខ Co. 1698/03E ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០០៣។ សកម្មភាពចម្បងរបស់ក្រុមហ៊ុន អង្គរ មីក្រូហិរញ្ញវត្ថុ (កម្ពុជា) ខូ អិលធីឌី គឺផ្តល់សេវាកម្មមីក្រូហិរញ្ញវត្ថុ ជូនប្រជាពលរដ្ឋក្រីក្រកម្ពុជា តាមរយៈការិយាល័យកណ្តាលរបស់ខ្លួននៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្តនានានៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ភាគហ៊ុន ៩៨,៥២% របស់ក្រុមហ៊ុនត្រូវបានកាន់កាប់ដោយក្រុមហ៊ុន Concern Worldwide (Dublin) ។

ក្រុមហ៊ុនត្រូវបានបង្កើតឡើងជាដំបូងនៅក្នុងឆ្នាំ១៩៩៩ ដែលមានឈ្មោះថា Thanakea Ponleu Thmey (ហៅកាត់ថា "TPT" ដែលជាគម្រោងរបស់ Concern Worldwide (Dublin) នៅប្រទេសកម្ពុជា (ហៅកាត់ថា "CWC") ។ ទ្រព្យសកម្ម ទ្រព្យអកម្ម និងជំនួយបង្គរទាំងអស់របស់ TPT ត្រូវបានផ្ទេរទៅអោយក្រុមហ៊ុន នៅថ្ងៃទី១ ខែកក្កដា ឆ្នាំ២០០៣ ដោយការបោះផ្សាយជាភាគហ៊ុន។ ក្រុមហ៊ុនបានចាប់ផ្តើមធ្វើពាណិជ្ជកម្មនៅកាលបរិច្ឆេទដែលទ្រព្យសម្បត្តិបានផ្ទេរ។

នៅថ្ងៃទី២៥ ខែមករា ឆ្នាំ២០១០ ក្រុមហ៊ុនបានទទួលអាជ្ញាប័ណ្ណ ពីធនាគារជាតិ នៃកម្ពុជា ជាគ្រឹះស្ថានទទួលប្រាក់បញ្ញើមីក្រូហិរញ្ញវត្ថុ (ហៅកាត់ថា "MDI") ដើម្បីប្រតិបត្តិអាជីវកម្មទទួលប្រាក់បញ្ញើ ។

ក្រុមហ៊ុន Concern Worldwide មានបំណងបញ្ចូលភាគហ៊ុនរបស់ខ្លួនរហូតដល់ទៅ ៩០% ទៅក្នុងគម្រោងមីក្រូហិរញ្ញវត្ថុជំនាញមួយ ដែលស្ថិតនៅក្រោមការអនុម័តរបស់អាជ្ញាធរច្បាប់។ សមាជិកក្រុមប្រឹក្សាភិបាល ៣រូបរបស់ក្រុមហ៊ុន នឹងក្លាយទៅជាភាគទុនិកនៃគម្រោងដែលបានស្នើសុំនេះ។

ក្រុមហ៊ុន ផ្តល់សេវាកម្មឥណទានទៅអោយគ្រួសារជនក្រីក្រ តាមរយៈការិយាល័យកណ្តាលរបស់ខ្លួន និងតាមរយៈសាខាចំនួន ២២ ដែលមានទីតាំងនៅខេត្តបន្ទាយមានជ័យ ខេត្តបាត់ដំបង ខណ្ឌដង្កោរ ខេត្តកំពង់ចាម ខេត្តកំពង់ឆ្នាំង ខេត្តកំពង់ស្ពឺ ខេត្តកំពង់ធំ ខេត្តកណ្តាល ខេត្តក្រចេះ ខេត្តកំពត ខេត្តមណ្ឌលគីរី ស្រុកមុខកំពូល ខេត្តឧត្តរមានជ័យ ខេត្តព្រះវិហារ ខេត្តព្រៃវែង ខេត្តពោធិ៍សាត់ ខេត្តរតនៈគិរី ខេត្តសៀមរាប ខេត្តព្រះសីហនុ ខេត្តស្ទឹងត្រែង ខេត្តស្វាយរៀង និងខេត្តតាកែវ។ ក្រុមហ៊ុនមានគោលការណ៍ណែនាំជាចម្បង ដូចខាងក្រោម :

- AMK នឹងផ្តល់សេវាមីក្រូហិរញ្ញវត្ថុដល់ប្រជាជនក្រីក្រនៅក្នុងប្រទេសកម្ពុជា ដែលមានវិន័យហិរញ្ញវត្ថុរឹងមាំនៅគ្រប់កម្រិត។
- AMK ប្តេជ្ញាបើកទូលាយ និងអោយមានតម្លាភាពនូវគ្រប់ផ្នែកទាំងអស់នៃការគ្រប់គ្រង និងប្រតិបត្តិការ។

## ក្រុមហ៊ុន អេ អឹម ខេ មីក្រូហិរញ្ញវត្ថុ (កម្ពុជា) ខូ អិលធីឌី

## កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ
## សម្រាប់ការិយបរិច្ឆេទដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១១

## ១. ព័ត៌មានទូទៅ (ត)

- AMK ប្តេជ្ញាធ្វើការអភិវឌ្ឍន៍ ដំណើរការ/សេវាកម្ម និងប្រកាន់ខ្ជាប់នូវអត្តចរិត និងស្តង់ដារដើម្បីធានាអោយបាននូវការបម្រើសង្គមប្រកបដោយប្រសិទ្ធភាពខ្ពស់ ដោយរួមទាំងការការពារអតិថិជន។
- AMK គឺជាគ្រឹះស្ថានរៀនសូត្រ ដែលការផ្លាស់ប្តូរ និងការចែករំលែកនូវព័ត៌មានដ៏សមស្រប ចូលរួមចំណែកដល់ការអភិវឌ្ឍន៍បុគ្គលិក ការបណ្តុះបណ្តាល ព្រមទាំងចូលរួមចំណែកក្នុងការកែលម្អគោលការណ៍និងប្រព័ន្ធ។

បច្ចុប្បន្ន ការិយាល័យចុះបញ្ជីរបស់ក្រុមហ៊ុន មានទីតាំងស្ថិតនៅអគារលេខ ៤៤២ ផ្លូវ ១៩៣ សង្កាត់ទួលស្វាយព្រៃ១ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

ក្រុមប្រឹក្សាភិបាលបានអនុម័ត អោយចេញផ្សាយរបាយការណ៍ហិរញ្ញវត្ថុនេះ នៅថ្ងៃទី២១ ខែមីនា ឆ្នាំ២០១២។

## ២. សេចក្តីសង្ខេបគោលការណ៍គណនេយ្យសំខាន់ៗ

គោលការណ៍គណនេយ្យសំខាន់ៗ ដែលបានអនុវត្តក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុនេះ ត្រូវបានបង្ហាញជូនដូចខាងក្រោម។ គោលការណ៍ទាំងនេះ ត្រូវបានអនុវត្តយ៉ាងស៊ីសង្វាក់គ្នា គ្រប់ឆ្នាំដែលបានបង្ហាញជូនទាំងអស់ លើកលែងតែមានការបញ្ជាក់ផ្សេងពីនេះ។

### ២.១ មូលដ្ឋាននៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ

របាយការណ៍ហិរញ្ញវត្ថុនេះ ត្រូវបានរៀបចំដោយអនុលោមទៅតាមគោលការណ៍ណែនាំ របស់ធនាគារជាតិនៃកម្ពុជា (ហៅកាត់ថា "ធនាគារកណ្តាល") និងស្តង់ដារគណនេយ្យកម្ពុជា (ហៅកាត់ថា "CAS")។ ក្នុងការប្រើប្រាស់ CAS ក្រុមហ៊ុនក៏បានប្រើ ស្តង់ដារទាក់ទងនឹង របាយការណ៍ហិរញ្ញវត្ថុកម្ពុជា CFRS 7 ស្តីពី "ឧបករណ៍ហិរញ្ញវត្ថុ : ការលាតត្រដាងព័ត៌មាន" ផងដែរ។ គោលការណ៍គណនេយ្យដែលបានប្រើប្រាស់ អាចមានភាពខុសគ្នាពីគោលការណ៍គណនេយ្យដែលត្រូវបានទទួលស្គាល់ និង ប្រើប្រាស់ជាទូទៅនៅតាមបណ្តាប្រទេស និងយុត្តាធិការផ្សេងៗ។ របាយការណ៍ហិរញ្ញវត្ថុដែលបានភ្ជាប់មកជាមួយនេះ មិនមានបំណងបង្ហាញអំពីស្ថានភាពហិរញ្ញវត្ថុ លទ្ធផលហិរញ្ញវត្ថុ និង ចលនាសាច់ប្រាក់ ដោយអនុលោមទៅតាមយុត្តាធិការណាផ្សេង ក្រៅពីព្រះរាជាណាចក្រកម្ពុជានោះទេ។ ដូចនេះ របាយការណ៍ហិរញ្ញវត្ថុទាំងនេះ សម្រាប់បង្ហាញចំពោះតែអ្នកដែលបានជ្រាបអំពីគោលការណ៍គណនេយ្យ នីតិវិធី និងការអនុវត្តនៅក្នុងព្រះរាជាណាចក្រកម្ពុជាតែប៉ុណ្ណោះ។

របាយការណ៍ហិរញ្ញវត្ថុត្រូវបានរៀបចំឡើងជាប្រាក់រៀលខ្មែរ ("រៀល") ដោយប្រើប្រាស់វិធីសាស្ត្រថ្លៃដើម។

## ២. សេចក្តីសង្ខេបគោលការណ៍គណនេយ្យសំខាន់ៗ (ត)

### ២.១ មូលដ្ឋាននៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ (ត)

ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ដែលស្របទៅតាមគោលការណ៍ណែនាំរបស់ធនាគារកណ្តាល និង CAS តម្រូវ អោយប្រើប្រាស់ការប៉ាន់ស្មាន និងការសន្មត ដែលមានផលប៉ះពាល់ដល់ចំនួនទ្រព្យសកម្ម និងទ្រព្យអកម្ម និងការលាតត្រដាងទ្រព្យសកម្ម និងទ្រព្យអកម្មយថាភាព ដែលបានរាយការណ៍ គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍ហិរញ្ញវត្ថុ និងប៉ះពាល់ដល់ចំនួននៃចំណូល និងចំណាយ ដែលបានរាយការណ៍នៅក្នុងអំឡុងពេលនៃការធ្វើរបាយការណ៍នេះ។ ទោះបីជាការប៉ាន់ស្មានទាំងនេះ ផ្អែកទៅលើការយល់ដឹងខ្ពស់របស់គណៈគ្រប់គ្រងទៅលើព្រឹត្តិការណ៍ និង សកម្មភាពផ្សេងៗ នាពេលបច្ចុប្បន្នក៏ដោយ ក៏លទ្ធផលជាក់លាក់ចុងក្រោយអាចខុសពីការប៉ាន់ស្មានទាំងនេះ។ ផ្នែកដែលទាក់ទងនឹងកម្រិតខ្ពស់នៃការវិនិច្ឆ័យ ឬភាពស្មុគស្មាញ ឬផ្នែកដែលការសន្មត និងការប៉ាន់ស្មានមានលក្ខណៈជាសារវន្តចំពោះរបាយការណ៍ហិរញ្ញវត្ថុ ត្រូវបានលាតត្រដាងនៅក្នុងកំណត់សម្គាល់ ៣។

តួលេខប្រៀបធៀបត្រូវបានកែតម្រូវដើម្បីអោយស្របទៅនឹងបម្រែបម្រួលនៃការបង្ហាញក្នុងឆ្នាំបច្ចុប្បន្ន នៅពេលដែលមានភាពចាំបាច់។

### ២.២ រូបិយប័ណ្ណបរទេស

#### ក. រូបិយប័ណ្ណគោល និងរូបិយប័ណ្ណសម្រាប់បង្ហាញ

គណនីទាំងអស់ដែលមាននៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ត្រូវបានវាស់តម្លៃដោយប្រើប្រាស់រូបិយ-ប័ណ្ណនៃបរិយាកាសសេដ្ឋកិច្ចចម្បង ដែលក្រុមហ៊ុនធ្វើប្រតិបត្តិការ (ហៅកាត់ថា "រូបិយប័ណ្ណគោល")។ របាយការណ៍ហិរញ្ញវត្ថុនេះ ត្រូវបានបង្ហាញជាប្រាក់រៀលខ្មែរ ("រៀល") ដែលជារូបិយប័ណ្ណគោល និងរូបិយប័ណ្ណសម្រាប់បង្ហាញរបស់ក្រុមហ៊ុន។ រូបិយប័ណ្ណគោលរបស់ក្រុមហ៊ុនគឺជាប្រាក់រៀល ដោយសារវាមានឥទ្ធិពលជាសារវន្តដល់ប្រតិបត្តិការរបស់ក្រុមហ៊ុន។

#### ខ. ការបង្ហាញជាប្រាក់ដុល្លារអាមេរិក

ក្រុមហ៊ុនបានបង្ហាញរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួនជាប្រាក់ដុល្លារអាមេរិក ("US$") ដោយកត់ត្រាពីប្រាក់រៀលទៅប្រាក់ដុល្លារអាមេរិក មានដូចខាងក្រោម ៖

- ទ្រព្យសកម្មនិងទ្រព្យអកម្មដែលបានបង្ហាញនៅក្នុងតារាងតុល្យការនីមួយៗ និងមូលធនភាគទុនិកត្រូវបានកត់ត្រាតាមអត្រាចុងគ្រា នាកាលបរិច្ឆេទតារាងតុល្យការ។

## ២. សេចក្តីសង្ខេបគោលការណ៍គណនេយ្យសំខាន់ៗ (ត)

### ២.២ រូបិយប័ណ្ណបរទេស (ត)

#### ខ. ការបង្ហាញជាប្រាក់ដុល្លារអាមេរិក (ត)

- របាយការណ៍លទ្ធផល និងរបាយការណ៍ចលនាសាច់ប្រាក់ ត្រូវបានកត់ត្រាជាប្រាក់ដុល្លារអាមេរិក ដោយប្រើប្រាស់អត្រាមធ្យមក្នុងឆ្នាំ។
- រាល់លទ្ធផលនៃលំអៀងពីការប្តូររូបិយប័ណ្ណដែលបានកើតឡើង ត្រូវបានកត់ត្រាដោយឡែកពីគ្នានៅក្នុងមូលធន។

#### គ. ប្រតិបត្តិការ និងសមតុល្យ

ប្រតិបត្តិការជារូបិយប័ណ្ណផ្សេងៗក្រៅពីប្រាក់រៀល ត្រូវបានកត់ត្រាទៅជាប្រាក់រៀល តាមអត្រាប្តូរប្រាក់ជាសកល នាកាលបរិច្ឆេទនៃប្រតិបត្តិការនោះ។ ចំណេញ និងខាតពីការប្តូររូបិយប័ណ្ណបរទេស ដោយសារការទូទាត់ប្រតិបត្តិការនិងពីការកត់ត្រាទ្រព្យសកម្ម និងទ្រព្យអកម្មរូបិយវត្ថុនានា ដែលកំណត់ជារូបិយប័ណ្ណផ្សេងៗក្រៅពីប្រាក់រៀល តាមអត្រាប្តូរប្រាក់នាជំណាច់ឆ្នាំ ត្រូវបានកត់ត្រានៅក្នុងរបាយការណ៍លទ្ធផល។

### ២.៣ សាច់ប្រាក់ និងសាច់ប្រាក់សមមូល

នៅក្នុងរបាយការណ៍ចលនាសាច់ប្រាក់ សាច់ប្រាក់ និងសាច់ប្រាក់សមមូល រួមមាន សាច់ប្រាក់ក្នុងដៃ ប្រាក់បញ្ញើដែលអាចដកមកវិញបាននៅធនាគារផ្សេងៗ ការវិនិយោគដែលមានលទ្ធភាពអាចបម្លែងជាសាច់ប្រាក់បានលឿនក្នុងរយៈពេលខ្លី ដែលមានកាលកំណត់បីខែ ឬតិចជាងនេះ និងឥណទានវិបារូបន៍។ នៅក្នុងតារាងតុល្យការ ឥណទានវិបារូបន៍ ត្រូវបានបង្ហាញនៅក្នុងប្រាក់កម្ចី។

### ២.៤ ឥណទានអតិថិជន

ឥណទានអតិថិជន ត្រូវបានរាយការណ៍ក្នុងតារាងតុល្យការ តាមចំនួនទឹកប្រាក់ដើម ដកចំនួនដែលបានជម្រះចេញពីបញ្ជី សំវិធានធនទូទៅ និងសំវិធានធនជាក់លាក់។ ឥណទានរយៈពេលខ្លី គឺជាឥណទានដែលមានកាលបរិច្ឆេទបង់សងក្នុង រយៈពេល១ឆ្នាំនៃកាលបរិច្ឆេទដែលឥណទានត្រូវបានធ្វើបុរេប្រទាន។ ឥណទានរយៈពេលវែង គឺជាឥណទានដែលមានកាលបរិច្ឆេទបង់សងចុងក្រោយ មានរយៈពេលលើសពី១ឆ្នាំ នៃកាលបរិច្ឆេទដែលឥណទានត្រូវបានធ្វើបុរេប្រទាន។

សំវិធានធនសម្រាប់ឥណទានអាក្រក់ និងសង្ស័យ ត្រូវបានវាយតម្លៃជារៀងរាល់ខែដោយគណៈគ្រប់គ្រង។ ផ្នែកដែលត្រូវគេវាយតម្លៃ រួមបញ្ចូលទំហំនៃប្រភេទឥណទាន ការខាតបង់ពីគ្រាមុន លក្ខខណ្ឌសេដ្ឋកិច្ចនាពេលបច្ចុប្បន្ន និងផលប៉ះពាល់លើអតិថិជន ស្ថានភាពហិរញ្ញវត្ថុរបស់អតិថិជននិងប្រតិបត្តិការឥណទានដែលទាក់ទងនឹងលក្ខខណ្ឌក្នុងកិច្ចសន្យា។

## ២. សេចក្តីសង្ខេបគោលការណ៍គណនេយ្យសំខាន់ៗ (ត)

### ២.៤ ឥណទានអតិថិជន (ត)

ឥណទានត្រូវបានជម្រះចេញពីបញ្ជីនៅក្នុងរបាយការណ៍លទ្ធផល នៅពេលដែលឥណទានដែលនៅសល់មិនទាន់បានបង់រយៈពេល១ឆ្នាំ ក្រោយកាលបរិច្ឆេទអាយុកាល ឬនៅពេលដែលអតិថិជនទទួលមរណៈភាព។ ឥណទានដែលបានជម្រះចេញពីបញ្ជី ត្រូវបានយកចេញពីប្រភេទឥណទានដែលនៅសល់ និងដកចេញពីសំវិធានធនសម្រាប់ការខាតបង់ឥណទាន។ ឥណទានអតិថិជនដែលប្រមូលបានមកវិញ បន្ទាប់ពីត្រូវបានជម្រះចេញពីបញ្ជីរួចហើយ ត្រូវបានកត់ត្រានៅក្នុងរបាយការណ៍លទ្ធផល។

### ២.៥ សំវិធានធនសម្រាប់ឥណទានអាក្រក់ និងសង្ស័យ

ក្រុមហ៊ុនបានអនុវត្តការធ្វើចំណាត់ថ្នាក់ឥណទាន និងសំវិធានធន តាមតម្រូវការរបស់ប្រកាសលេខ ធ៧-០២-១៨៦ប្រ.ក. ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០០២។ ប្រកាសនេះ តម្រូវអោយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទាំងឡាយធ្វើចំណាត់ថ្នាក់ ប្រភេទឥណទានរបស់ខ្លួនជា៤ថ្នាក់ ហើយត្រូវប្រាកដថាគ្រឹះស្ថានរបស់ខ្លួន បានបំពេញកាតព្វកិច្ចសំវិធានធនជាក់លាក់ អប្បបរមា ដូចខាងក្រោម ៖

| ចំណាត់ថ្នាក់ | ចំនួនថ្ងៃដែលផុតកំណត់ | សំវិធានធន |
|---|---|---|
| *ឥណទានរយៈពេលខ្លី (តិចជាង១ឆ្នាំ)* | | |
| ក្រោមស្តង់ដារ | ពី ៣១ថ្ងៃ ទៅ ៦០ថ្ងៃ | ១០% |
| សង្ស័យ | ពី ៦១ថ្ងៃ ទៅ ៩០ថ្ងៃ | ៣០% |
| បាត់បង់ | លើសពី ៩០ថ្ងៃ | ១០០% |
| *ឥណទានរយៈពេលវែង (លើសពី១ឆ្នាំ)* | | |
| ក្រោមស្តង់ដារ | ពី ៣១ថ្ងៃ ទៅ ១៨០ថ្ងៃ | ១០% |
| សង្ស័យ | ពី ១៨១ថ្ងៃ ទៅ ៣៦០ថ្ងៃ | ៣០% |
| បាត់បង់ | លើសពី ៣៦០ថ្ងៃ | ១០០% |

## ២. សេចក្តីសង្ខេបគោលការណ៍គណនេយ្យសំខាន់ៗ (ត)

### ២.៥ សំវិធានធនឥណទានអាក្រក់ និងសង្ស័យ (ត)

សំវិធានធនជាក់លាក់ដែលត្រូវបានគណនា ជាចំនួនភាគរយនៃឥណទានដែលនៅសល់ នៅពេលដែលឥណទានត្រូវបានធ្វើចំណាត់ថ្នាក់ ដោយមិនរាប់បញ្ចូលការប្រាក់បង្គរ ហើយត្រូវបានចាត់ជាបន្ទុកចំណាយ។

ក្រៅពីសំវិធានធនខាងលើ សំវិធានធនបន្ថែមលើឥណទានបាត់បង់សម្រាប់ឥណទានអាក្រក់ និងសង្ស័យ ត្រូវបានធ្វើឡើងតាមអត្រា១% លើឥណទានដំណើរការល្អដែលនៅមិនទាន់ទូទាត់ទាំងអស់ ដោយមិនរាប់បញ្ចូលឥណទានផ្តល់ដល់បុគ្គលិក។

### ២.៦ ទ្រព្យសម្បត្តិ និងបរិក្ខារ

ទ្រព្យសម្បត្តិ និងបរិក្ខារ ត្រូវបានកត់ត្រាតាមថ្លៃដើម ដករំលស់បង្គរ និងការចុះថយតម្លៃបង្គរ។ ថ្លៃដើម រួមមានចំណាយផ្ទាល់ផ្សេងៗ ក្នុងការទិញទ្រព្យសកម្មទាំងនោះ។

រំលស់លើទ្រព្យសម្បត្តិ និងបរិក្ខារ ត្រូវបានកត់ត្រាជាបន្ទុកនៅក្នុងរបាយការណ៍លទ្ធផល តាមមូលដ្ឋាន រំលស់ថេរលើអាយុកាលប្រើប្រាស់ប៉ាន់ស្មាននៃទ្រព្យសកម្មនីមួយៗនោះ តាមអត្រាដូចខាងក្រោម :

| | |
|---|---|
| យានយន្ត | ៨ ឆ្នាំ |
| ម៉ូតូ | ៥ ឆ្នាំ |
| កុំព្យូទ័រ និងបរិក្ខារការិយាល័យ | ៣ ឆ្នាំ ទៅ ៤ ឆ្នាំ |

តម្លៃនៅសល់ និងការប៉ាន់ស្មានអាយុកាលប្រើប្រាស់របស់ទ្រព្យសម្បត្តិ ត្រូវបានត្រួតពិនិត្យ ឬធ្វើវិសោធនកម្ម នៅពេលដែលមានភាពចាំបាច់ នូវរាល់កាលបរិច្ឆេទតារាងតុល្យការ។

ចំណាយបន្តបន្ទាប់ផ្សេងៗ ត្រូវបានកត់ត្រាបញ្ចូលទៅក្នុងតម្លៃនៅសល់នៃទ្រព្យនោះ ឬត្រូវបានកត់ត្រាជាទ្រព្យដាច់ដោយឡែកតាមការជាក់ស្តែង នៅពេលដែលមានភាពប្រាកដថា ផលប្រយោជន៍សេដ្ឋកិច្ចនាពេលអនាគតនៃទ្រព្យនោះ នឹងហូរចូលមកក្នុងក្រុមហ៊ុន ហើយថ្លៃដើមនៃទ្រព្យនោះ អាចត្រូវបានវាស់វែងគួរអោយជឿជាក់បានតែប៉ុណ្ណោះ។ ចំណាយបន្តបន្ទាប់ផ្សេងទៀត ត្រូវបានកត់ត្រាជាបន្ទុកចំណាយក្នុងឆ្នាំដែលប្រតិបត្តិការនោះកើតឡើង។

នៅពេលដែលតម្លៃនៅសល់របស់ទ្រព្យសម្បត្តិ ច្រើនជាងតម្លៃប៉ាន់ស្មានដែលអាចយកមកវិញបាន វាត្រូវបានកត់ត្រាភ្លាមៗក្នុងតម្លៃដែលអាចយកមកវិញបាន។ តម្លៃប៉ាន់ស្មានដែលអាចយកមកវិញបាន គឺជាចំនួនច្រើនជាងនៃលំហូរសាច់ប្រាក់ដែលបានធ្វើអប្បហារពីការបន្តប្រើប្រាស់ទ្រព្យសម្បត្តិ និងចំនួនដែលអាចទទួលបានពីការលក់ទ្រព្យសម្បត្តិ ដកថ្លៃដើមនៃការជម្រះចេញរបស់ទ្រព្យសម្បត្តិនោះ។

## ២. សេចក្តីសង្ខេបគោលការណ៍គណនេយ្យសំខាន់ៗ (ត)

### ២.៦ ទ្រព្យសម្បត្តិ និងបរិក្ខារ (ត)

ចំណេញ ឬខាតដែលកើតឡើងពីទ្រព្យសម្បត្តិ និងបរិក្ខារដែលបានជម្រះចេញ ឬលែងប្រើប្រាស់ត្រូវបានកំណត់ថាជាលំអៀងរវាងការប៉ាន់ស្មាននៃការលក់ចេញសុទ្ធ ទៅនឹងតម្លៃនៅសល់របស់ទ្រព្យនោះ ហើយត្រូវបានកត់ត្រាក្នុងរបាយការណ៍លទ្ធផល នាកាលបរិច្ឆេទជម្រះចេញ ឬលែងប្រើប្រាស់របស់ទ្រព្យនោះ។

### ២.៧ ទ្រព្យសកម្មអរូបី

ទ្រព្យសកម្មអរូបី រួមមានអាជ្ញាប័ណ្ណកម្មវិធីកុំព្យូទ័រដែលបានទិញនិងចំណាយពាក់ព័ន្ធផ្សេងៗ ត្រូវបានរាយការណ៍តាមថ្លៃដើម ដករំលស់បង្គរ និងការខាតបង់ដែលបណ្តាលមកពីការថយចុះតម្លៃ។ អាជ្ញាប័ណ្ណកម្មវិធីកុំព្យូទ័រដែលបានទិញត្រូវបានគេធ្វើមូលធនកម្មតាមមូលដ្ឋានថ្លៃដើម ដែលបានកើតឡើងក្នុងការទិញកម្មវិធីនោះមកប្រើប្រាស់។ ថ្លៃដើមនេះត្រូវបានគេធ្វើរំលស់រយៈពេល ៥ឆ្នាំ ដោយប្រើវិធីសាស្ត្ររំលស់ថេរ។

ថ្លៃដើមទាក់ទងនឹងការថែទាំកម្មវិធីកុំព្យូទ័រ ត្រូវបានកត់ត្រាជាបន្ទុកចំណាយ នៅពេលដែលប្រតិបត្តិការនោះបានកើតឡើង។

### ២.៨ បម្រែបម្រួលក្នុងការប៉ាន់ស្មានគណនេយ្យ

ក្នុងអំឡុងឆ្នាំ ក្រុមហ៊ុនបានធ្វើការផ្លាស់ប្តូរការប៉ាន់ស្មានគណនេយ្យនៃអាយុកាលប្រើប្រាស់ និងវិធីសាស្ត្រសម្រាប់ទ្រព្យសកម្មរូបី និងអរូបី ។ អាយុកាលប្រើប្រាស់របស់ទ្រព្យសកម្មមួយចំនួន ត្រូវបានផ្លាស់ប្តូរ និងវិធីសាស្ត្រក្នុងការធ្វើរំលស់ក៏បានផ្លាស់ប្តូរពីវិធីសាស្ត្ររំលស់ថយទៅវិធីសាស្ត្ររំលស់ថេរវិញ។ គណៈគ្រប់គ្រងយល់ឃើញថា ការប្រើប្រាស់វិធីសាស្ត្ររំលស់ថ្មីលើអាយុកាលប្រើប្រាស់នេះ ផ្តល់នូវព័ត៌មានដែលពាក់ព័ន្ធច្រើន ហើយដែលអាចជឿជាក់បាន ព្រោះវាធ្វើអោយមានភាពច្បាស់លាស់ទៅលើអាយុកាលប្រើប្រាស់របស់ទ្រព្យសកម្ម និងមានលក្ខណៈ សមស្របទៅនឹងប្រតិបត្តិការរបស់ក្រុមហ៊ុន។ ប្រសិទ្ធភាពនៃការផ្លាស់ប្តូរនេះ ត្រូវបានចាប់អនុវត្ត ពីថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១១។ ប្រសិនបើការប៉ាន់ស្មានគណនេយ្យ មិនត្រូវបានផ្លាស់ប្តូរ នោះចំណាយលើរំលស់រូបី ដែលបានរាយការណ៍ សម្រាប់ឆ្នាំ២០១១ មានចំនួនខ្ពស់ជាង ២៣លានរៀល និង ចំណាយលើរំលស់អរូបី មានចំនួនខ្ពស់ជាង ១៦លានរៀល។

## ២. សេចក្តីសង្ខេបគោលការណ៍គណនេយ្យសំខាន់ៗ (ត)

### ២.៨ បម្រែបម្រួលក្នុងការប៉ាន់ស្មានគណនេយ្យ (ត)

| បម្រែបម្រួលក្នុងវិធីសាស្ត្ររំលស់ និងអត្រាប្រចាំឆ្នាំ | **វិធីសាស្ត្ររំលស់ថយ** | **វិធីសាស្ត្ររំលស់ថេរ** |
|---|---|---|
| *ទ្រព្យសម្បត្តិ និងបរិក្ខារ :* | | |
| យានយន្ត | ២៥% | ១២,៥០% |
| ម៉ូតូ | ២៥% | ២០,០០% |
| កុំព្យូទ័រ និងបរិក្ខារការិយាល័យ | ៥០% | ២៥,០០% - ៣៣,៣៣% |
| *ទ្រព្យសកម្មអរូបី* | | |
| កម្មវិធីកុំព្យូទ័រផ្សេងៗ | ៥០% | ២០% |

### ២.៩ ការថយចុះតម្លៃ នៃទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ

ទ្រព្យសកម្មទាំងឡាយណាដែលមានអាយុកាលប្រើប្រាស់មិនកំណត់ មិនត្រូវបានធ្វើរំលស់ទេ ហើយវាត្រូវបានគេត្រួតពិនិត្យប្រចាំឆ្នាំ ដើម្បីរកការថយចុះតម្លៃរបស់វា។ ទ្រព្យសកម្មទាំងឡាយណា ដែលត្រូវគេធ្វើរំលស់ ត្រូវបានត្រួតពិនិត្យរកការថយចុះតម្លៃរបស់វា នៅពេលដែលមានព្រឹត្តិការណ៍ ឬការផ្លាស់ប្តូរកាលៈទេសៈណាមួយ ចង្អុលបង្ហាញថាតម្លៃនៅសល់របស់វា នឹងមិនអាចស្រង់មកវិញបាន។ ការខាតបង់បណ្តាលមកពីការថយចុះតម្លៃ ត្រូវបានកត់ត្រាតាមចំនួនលំអៀង រវាងតម្លៃនៅសល់នៃទ្រព្យនោះ ធៀបជាមួយតម្លៃដែលអាចស្រង់មកវិញបាន។ តម្លៃដែលអាចស្រង់មកវិញបាន គឺជាតម្លៃមួយណាដែលខ្ពស់ជាង រវាងតម្លៃទីផ្សារនៃទ្រព្យនោះ ដកចំណាយក្នុងការលក់ និងតម្លៃនៅប្រើប្រាស់បាន។ ក្នុងការវាយតម្លៃដើម្បីរកការថយចុះ ទ្រព្យសម្បត្តិទាំងឡាយ ត្រូវបានចាត់ជាក្រុមតូចៗបំផុត ដើម្បីកំណត់ពីលំហូរសាច់ប្រាក់នីមួយៗ (ឯកត្តាបង្កើតសាច់ប្រាក់ "cash-generating units")។

ខាតបណ្តាលមកពីការថយចុះតម្លៃ ត្រូវបានកត់ត្រាប្រសិនបើតម្លៃនៅសល់នៃទ្រព្យ ឬ ឯកត្តាបង្កើតសាច់ប្រាក់របស់វាលើសពីតម្លៃប៉ាន់ស្មានដែលអាចស្រង់មកវិញបាន។ ខាតបណ្តាលមកពីការថយចុះតម្លៃ ត្រូវបានកត់ត្រាក្នុងរបាយការណ៍លទ្ធផល។

### ២.១០ ប្រាក់បញ្ញើ

ប្រាក់បញ្ញើរបស់អតិថិជនត្រូវបានកត់ត្រាទុកតាមតម្លៃនៃប្រាក់តម្កល់។

## ២. សេចក្តីសង្ខេបគោលការណ៍គណនេយ្យសំខាន់ៗ (ត)

### ២.១១ ប្រាក់កម្ចី

ប្រាក់កម្ចី ត្រូវបានកត់ត្រាតាមចំនួនប្រាក់ដើម ដែលមិនទាន់ទូទាត់ ។ កម្រៃផ្សេងៗ ដែលបានចំណាយដើម្បីទទួលបានប្រាក់កម្ចី ត្រូវបានធ្វើមូលធនកម្ម និងធ្វើរំលស់លើរយៈពេលនៃប្រាក់កម្ចីនោះ ដោយប្រើវិធីសាស្ត្ររំលស់ថេរ ។

### ២.១២ សំវិធានធន

សំវិធានធន ត្រូវបានកត់ត្រានៅពេលដែលក្រុមហ៊ុនមានកាតព្វកិច្ចផ្លូវច្បាប់ ឬកាតព្វកិច្ចដែលក្រុមហ៊ុនបានបង្កើតឡើងនាពេលបច្ចុប្បន្ន ដែលជាលទ្ធផលនៃព្រឹត្តិការណ៍ពីអតីតកាល វាទំនងជាអាចតម្រូវអោយមានការចំណាយធនធាន ដើម្បីទូទាត់កាតព្វកិច្ចនោះ ហើយចំនួនទឹកប្រាក់ត្រូវបានប៉ាន់ស្មានគួរអោយជឿជាក់បាន ។

នៅពេលដែលមានកាតព្វកិច្ចស្រដៀងគ្នាច្រើន កម្រិតនៃលំហូរចេញដើម្បីទូទាត់កាតព្វកិច្ចនោះ ត្រូវបានកំណត់ដោយគិតទៅលើចំណាត់ថ្នាក់នៃកាតព្វកិច្ចនោះទាំងមូល ។ សំវិធានធនត្រូវបានកត់ត្រា ទោះបីជាកម្រិតលំហូរចេញនៃខ្ទង់ណាមួយ នៅក្នុងចំណាត់ថ្នាក់កាតព្វកិច្ចដូចគ្នានោះ មានចំនួនតូចក៏ដោយ ។

សំវិធានធនត្រូវបានវាស់វែងឡើងវិញតាមតម្លៃបច្ចុប្បន្ន នៃចំណាយដែលរំពឹងថាត្រូវទូទាត់កាតព្វកិច្ចនោះ ដោយប្រើអត្រាមុនបង់ពន្ធ ដើម្បីឆ្លុះបញ្ចាំងការវាយតម្លៃទីផ្សារបច្ចុប្បន្ន នៃតម្លៃសាច់ប្រាក់គិតតាមពេលវេលា និងហានិភ័យជាក់លាក់ផ្សេងៗនៃកាតព្វកិច្ចនោះ ។ ការកើនឡើងនៃសំវិធានធន ដោយសារពេលវេលាដែលបានកន្លងផុត ត្រូវបានកត់ត្រាជាចំណាយលើការប្រាក់ ។

### ២.១៣ សំវិធានធនសម្រាប់មូលនិធិសោធននិវត្តន៍របស់បុគ្គលិក

ក្រុមហ៊ុនផ្តល់អត្ថប្រយោជន៍ដល់បុគ្គលិករបស់ខ្លួន ក្រោមគោលការណ៍ មូលនិធិសោធននិវត្តន៍ ។ បុគ្គលិកដែលបំពេញសេវាកម្មអោយក្រុមហ៊ុនលើសពីរយៈពេល ៣ខែទៅ មានសិទ្ធិចូលរួមក្នុងមូលនិធិសោធននិវត្តន៍នេះ ។ មូលនិធិនេះមានប្រភពមកពីកត្តាដូចខាងក្រោម :

- បុគ្គលិកចូលរួមចំណែក ៣% នៃប្រាក់បៀវត្សប្រចាំខែរបស់ខ្លួន ហើយក្រុមហ៊ុនចូលរួមចំណែក ៦% ។ ការរួមចំណែករបស់ក្រុមហ៊ុន ត្រូវបានកត់ត្រាជាបន្ទុកចំណាយនៅក្នុងរបាយការណ៍លទ្ធផល ។
- ក្រុមហ៊ុនផ្តល់ការប្រាក់លើសមតុល្យបង្គរនៃមូលនិធិសោធននិវត្តន៍ ដែលត្រូវបានគណនាតាមអត្រា ៧% ក្នុងមួយឆ្នាំ ។ ការប្រាក់នេះ ត្រូវបានកត់ត្រាជាបន្ទុកចំណាយនៅក្នុងរបាយការណ៍លទ្ធផល ។

## ២. សេចក្តីសង្ខេបគោលការណ៍គណនេយ្យសំខាន់ៗ (ត)

### ២.១៣ សំវិធានធនសម្រាប់មូលនិធិសោធននិវត្តន៍របស់បុគ្គលិក (ត)

មូលនិធិសោធនិវត្តន៍ នឹងត្រូវទូទាត់ជូនបុគ្គលិក (បុគ្គលិកដែលបានចូលរួមចំណែកក្នុងមូលនិធិ) នៅពេលដែលបុគ្គលិកចូលនិវត្ត លាឈប់ពីការងារ ឬត្រូវបញ្ឈប់ពីការងារ។ ការរួមចំណែករបស់បុគ្គលិក ព្រមទាំងការប្រាក់ ត្រូវបានក្រុមហ៊ុនទូទាត់ជូនយ៉ាងពេញលេញ។

បុគ្គលិកទាំងឡាយណា ដែលត្រូវបានក្រុមហ៊ុនបញ្ឈប់ពីការងារ ដោយសារការប្រព្រឹត្តខុសឆ្គងធ្ងន់ធ្ងរ ត្រូវទទួលបានមូលនិធិនេះ ត្រឹមតែចំណែកដែលបុគ្គលិករូបនោះបានបង់ រួមទាំងការប្រាក់ប៉ុណ្ណោះ ដោយមិនគិតលើអតីតភាពការងាររបស់បុគ្គលិករូបនោះឡើយ។

### ២.១៤ ពន្ធលើប្រាក់ចំណេញក្នុងឆ្នាំ និងពន្ធលើប្រាក់ចំណេញពន្យារ

បន្ទុកពន្ធលើប្រាក់ចំណេញ ត្រូវបានគណនាតាមមូលដ្ឋានច្បាប់សារពើពន្ធ ដែលបានអនុម័តរួច ឬអនុម័តរួចមួយផ្នែកធំ គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នៅក្នុងប្រទេសកម្ពុជា ដែលជាប្រទេសដែលក្រុមហ៊ុនធ្វើប្រតិបត្តិការ និងបង្កើតប្រាក់ចំណេញជាប់ពន្ធ។

ពន្ធពន្យារ ត្រូវបានកត់ត្រា តាមវិធីសាស្ត្រទ្រព្យអកម្មក្នុងតារាងតុល្យការ លើលំអៀងបណ្តោះអាសន្ន នៃតម្លៃនៅសល់របស់ទ្រព្យសកម្ម និងទ្រព្យអកម្មនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ធៀបនឹងចំនួនដែលបានប្រើប្រាស់សម្រាប់ការគណនាពន្ធ។ ពន្ធពន្យារ ត្រូវបានវាស់វែងតាមអត្រាពន្ធដែលបានអនុម័តរួច ឬអនុម័តរួចមួយផ្នែកធំ គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍ ដែលរំពឹងថានឹងត្រូវអនុវត្តចំពោះលំអៀងបណ្តោះអាសន្ន នៅពេលដែលវាត្រូវកត់ត្រាបញ្ច្រាសមកវិញ។ ពន្ធពន្យារជាទ្រព្យសកម្ម ត្រូវបានទូទាត់ជាមួយនឹងពន្ធពន្យារទ្រព្យអកម្ម ប្រសិនបើក្រុមហ៊ុនមានសិទ្ធិតាមផ្លូវច្បាប់ ដើម្បីទូទាត់បំណុលពន្ធក្នុងឆ្នាំ ហើយវាទាក់ទងនឹងពន្ធលើប្រាក់ចំណេញ ដែលកំណត់ដោយអាជ្ញាធរពន្ធដារតែមួយ ទៅលើក្រុមហ៊ុនជាប់ពន្ធតែមួយ។

ពន្ធពន្យារជាទ្រព្យសកម្មត្រូវបានកត់ត្រា លុះត្រាតែមានភាពប្រាកដថា ក្រុមហ៊ុននឹងមានប្រាក់ចំណេញជាប់ពន្ធនាពេលអនាគត សម្រាប់យកលំអៀងបណ្តោះអាសន្នមកប្រើប្រាស់។ ពន្ធពន្យារជាទ្រព្យសកម្មត្រូវបានត្រួតពិនិត្យនៅរៀងរាល់កាលបរិច្ឆេទរបាយការណ៍នីមួយៗ ហើយត្រូវបានកត់ត្រាបន្ថយ ប្រសិនបើមិនមានភាពប្រាកដថានឹងមានអត្ថប្រយោជន៍ ពន្ធពាក់ព័ន្ធ ត្រូវបានទទួលស្គាល់។

## ២. សេចក្តីសង្ខេបគោលការណ៍គណនេយ្យសំខាន់ៗ (ត)

### ២.១៥ ការកត់ត្រាចំណូល និងចំណាយ

ចំណូលពីការប្រាក់បានមកពីឥណទានផ្សេងៗ ត្រូវបានកត់ត្រាតាមមូលដ្ឋានបង្គរ។ នៅពេលដែលឥណទានក្លាយជា ឥណទានមិនដំណើរការ ការកត់ត្រាចំណូលពីការប្រាក់ត្រូវបានព្យួរទុកមួយរយៈ រហូតដល់ពេលដែលគេទទួលបានសាច់ប្រាក់ជាក់ស្តែង។

ចំណូលកម្រៃឥណទាន ត្រូវបានកត់ត្រាជាចំណូល នៅពេលដែលឥណទានត្រូវបានផ្តល់ទៅអោយអតិថិជន។ ចំណូលកម្រៃឥណទាន ត្រូវបានគណនាដោយប្រើអត្រាកម្រៃលើថ្លៃដើម។

ចំណាយ ត្រូវបានកត់ត្រាតាមមូលដ្ឋានបង្គរ។

### ២.១៦ ភតិសន្យាប្រតិបត្តិការ

ភតិសន្យា ដែលមួយផ្នែកធំនៃហានិភ័យ និងផលនៃកម្មសិទ្ធិលើទ្រព្យសម្បត្តិនេះ ត្រូវបានរក្សាដោយភាគីម្ចាស់ទ្រព្យ ត្រូវបានចាត់ថ្នាក់ជាភតិសន្យាប្រតិបត្តិការ។ ការទូទាត់ភតិសន្យាប្រតិបត្តិ ត្រូវបានកត់ត្រាជាបន្ទុកក្នុងរបាយការណ៍លទ្ធផល តាមមូលដ្ឋានថេរលើរយៈពេលនៃភតិសន្យានោះ។

### ២.១៧ តួលេខគត់

តួលេខដែលបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ត្រូវបានកាត់ខ្ទង់គត់ចំពោះប្រាក់ដុល្លារអាមេរិក និងកាត់ខ្ទង់ជាពាន់រៀល ចំពោះប្រាក់រៀល។

## ៣. ការប៉ាន់ស្មាន និងការវិនិច្ឆ័យគណនេយ្យសំខាន់ៗ

ក្រុមហ៊ុនធ្វើការប៉ាន់ស្មាន ការសន្មត និងការវិនិច្ឆ័យ ដែលមានផលប៉ះពាល់ដល់ចំនួនទ្រព្យសកម្ម និងទ្រព្យអកម្ម ដែលបានរាយការណ៍។ ការប៉ាន់ស្មាន ការសន្មត និងការវិនិច្ឆ័យ ត្រូវបានវាយតម្លៃជាបន្តបន្ទាប់ ដោយផ្អែកទៅតាមបទពិសោធន៍ក្នុងគ្រាកន្លងមក និងកត្តាផ្សេងៗទៀត រួមមានការរំពឹងទុកនៃព្រឹត្តិការណ៍នាពេលអនាគត ដែលគេជឿជាក់ថាមានភាពសមហេតុផល ទៅតាមកាលៈទេសៈផ្សេងៗ។

## ក្រុមហ៊ុន អេ្កស មីក្រូហិរញ្ញវត្ថុ (កម្ពុជា) ខូ អិលធីឌី

## កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ
## សម្រាប់ការិយបរិច្ឆេទដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១១

### ៣. ការប៉ាន់ស្មាន និងការវិនិច្ឆ័យគណនេយ្យសំខាន់ៗ (ត)

### ក. ការខាតបង់បណ្តាលមកពីការថយចុះតម្លៃ នៃឥណទានអតិថិជន

ក្រុមហ៊ុនអនុវត្តការធ្វើចំណាត់ថ្នាក់ឥណទាន និងសំវិធានធន តម្រូវទៅតាមប្រកាសលេខ ធ៧-០២-១៨៦ប្រ.ក. ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០០២ ស្តីពីការធ្វើចំណាត់ថ្នាក់ និងសំវិធានធនឥណទានអាក្រក់ និងសង្ស័យ។ ធនាគារជាតិនៃកម្ពុជា តម្រូវអោយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទាំងឡាយ ធ្វើចំណាត់ថ្នាក់ប្រភេទឥណទានរបស់ខ្លួនជា៣ថ្នាក់ ហើយត្រូវប្រាកដថា គ្រឹះស្ថានរបស់ខ្លួនបានបំពេញកាតព្វកិច្ចសំវិធានធនជាក់លាក់អប្បបរមា អាស្រ័យលើការធ្វើចំណាត់ថ្នាក់ពាក់ព័ន្ធ ដោយមិនគិតដល់ទ្រព្យសកម្ម ដែលបានដាក់ជាវត្ថុបញ្ចាំ (លើកលែងតែសាច់ប្រាក់)។ ការធ្វើចំណាត់ថ្នាក់ឥណទានតម្រូវអោយក្រុមហ៊ុន គិតពិចារណាទៅលើប្រវត្តិនៃការសងប្រាក់ និងលក្ខខណ្ឌហិរញ្ញវត្ថុ របស់អ្នកខ្ចី។

ក្រៅពីសំវិធានធនជាក់លាក់ សំវិធានធនបន្ថែមទូទៅសម្រាប់ឥណទានអាក្រក់ និងសង្ស័យ ត្រូវបានធ្វើឡើងតាមអត្រា ១% នៃឥណទានដំណើរការដែលនៅមិនទាន់ទូទាត់ទាំងអស់ ដោយមិនរាប់បញ្ចូលឥណទានទៅអោយបុគ្គលិក គិតត្រឹមដំណាច់ការិយបរិច្ឆេទ។

### ខ. ពន្ធលើប្រាក់ចំណេញ

ពន្ធត្រូវបានគណនា តាមមូលដ្ឋានបំណកស្រាយបច្ចុប្បន្ននៃបទប្បញ្ញត្តិពន្ធដារ។ ទោះជាយ៉ាងណាក៏ដោយ បទប្បញ្ញត្តិទាំងអស់នេះ មានការផ្លាស់ប្តូរពីមួយគ្រាទៅមួយគ្រា ហើយការសម្រេចជាចុងក្រោយលើចំនួនពន្ធ នឹងធ្វើឡើងបន្ទាប់ពីអធិការកិច្ចចុងក្រោយរបស់អគ្គនាយកដ្ឋានពន្ធដារ។

នៅពេលដែលលទ្ធផលពន្ធចុងក្រោយ ខុសគ្នាពីចំនួនដែលបានកត់ត្រាពីដំបូង ភាពលំអៀងនេះនឹងធ្វើអោយប៉ះពាល់ដល់ពន្ធលើប្រាក់ចំណេញ និងសំវិធានធនលើពន្ធពន្យារនៅក្នុងការិយបរិច្ឆេទ ដែលការកំណត់ពន្ធបានធ្វើឡើង។

### គ. ទ្រព្យសម្បត្តិ និងបរិក្ខារ

គណនេយ្យកម្មលើទ្រព្យសម្បត្តិ និងបរិក្ខារ ទាក់ទងនឹងការប្រើប្រាស់ការប៉ាន់ស្មាន ក្នុងការកំណត់អាយុកាលប្រើប្រាស់ប៉ាន់ស្មាន និងតម្លៃសំណល់របស់ទ្រព្យសកម្មទាំងនេះ។ ការកំណត់អាយុកាលប្រើប្រាស់ និងតម្លៃសំណល់របស់ទ្រព្យសកម្មទាំងនេះ គឺផ្អែកលើការវិនិច្ឆ័យរបស់គណៈគ្រប់គ្រង។ ដើម្បីធ្វើការវិនិច្ឆ័យ ក្រុមហ៊ុនវាយតម្លៃទ្រព្យសកម្មទៅលើកត្តាផ្សេងៗ ដូចជាទៅលើអាយុកាលប្រើប្រាស់របស់វា លើការខូចខាត បាក់បែកដោយធម្មជាតិដែលផ្អែកទៅលើប្រតិបត្តិការ កត្តាបរិស្ថាន និងបច្ចេកទេស ឬការឈប់ប្រើប្រាស់ដែលកើតឡើងពីបម្រែបម្រួល ឬការកែលំអ ក្នុងបច្ចេក-វិជ្ជាជាដើម។

## ក្រុមហ៊ុន អន្តរ មីក្រូហិរញ្ញវត្ថុ (កម្ពុជា) ខូ អិលធីឌី

## កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ
## សម្រាប់ការិយបរិច្ឆេទដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១១

## ៤. សាច់ប្រាក់ក្នុងដៃ

| | ២០១១ | | ២០១០ | |
|---|---|---|---|---|
| | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក |
| ការិយាល័យកណ្តាល | ១៤.១២១ | ៣.៤៩៦ | ២៣.៩៥៣ | ៥.៩១០ |
| សាខាផ្សេងៗ | ១.៥០៦.២៨៣ | ៣៧២.៩៣៥ | ៨០៦.៥៧៤ | ១៩៩.០០៧ |
| | ១.៥២០.៤០៤ | ៣៧៦.៤៣១ | ៨៣០.៥២៧ | ២០៤.៩១៧ |

ក្នុងការរៀបចំរបាយការណ៍ចលនាសាច់ប្រាក់ សាច់ប្រាក់ និងសាច់ប្រាក់សមមូល រួមមាន :

| | ២០១១ | | ២០១០ | |
|---|---|---|---|---|
| | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក |
| សាច់ប្រាក់ក្នុងដៃ | ១.៥២០.៤០៤ | ៣៧៦.៤៣១ | ៨៣០.៥២៧ | ២០៤.៩១៧ |
| សមតុល្យនៅធនាគារកណ្តាល | ១១៣.៤១៨ | ២៨.០៨១ | ១.៣៦៨.១០៦ | ៣៣៧.៥៥៤ |
| សមតុល្យនៅធនាគារផ្សេងៗ : | | - | | |
| គណនីចរន្ត | ១៤.៨៣០.២៤៤ | ៣.៦៧១.៧៦១ | ៩.៨៦៦.០៩៨ | ២.៤៣៤.២៧០ |
| ប្រាក់បញ្ញើរយៈពេលខ្លី (កាលបរិច្ឆេទ អាយុកាលតិចជាង ៣ខែ) | ៨.០៧៨.០០០ | ២.០០០.០០០ | ៧.០៥៣.០០០ | ១.៧៤០.១៩២ |
| ឥណទានវិបារូបន៍ | (៤.០៣៧.២១៨) | (៩៩៩.៥៥៩) | - | - |
| | ២០.៥០៤.៨៤៨ | ៥.០៧៦.៧១៤ | ១៩.១១៧.៧៣១ | ៤.៧១៦.៩៣៣ |

**កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ**
**សម្រាប់ការិយបរិច្ឆេទដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១១**

## ៥. សមតុល្យនៅធនាគារកណ្តាល

| | ២០១១ | | ២០១០ | |
|---|---|---|---|---|
| | **ពាន់រៀល** | **ដុល្លារអាមេរិក** | **ពាន់រៀល** | **ដុល្លារអាមេរិក** |
| ប្រាក់តម្កល់ដើមទុនតាមច្បាប់ | ៣.៤០៦.៩២៥ | ៨៤៣.៥០៧ | ៣.៤០៦.៩២៥ | ៨៤០.៥៩៣ |
| ប្រាក់បញ្ញើបម្រុង | ១.៣៣៥.០០០ | ៣៣០.៥២៧ | ៤៤០.០០០ | ១០៨.៥៦២ |
| គណនីចរន្តផ្សេងៗ | ១១៣.៤១៨ | ២៨.០៨១ | ១.៣៦៨.១០៦ | ៣៣៧.៥៥៤ |
| | ៤.៨៥៥.៣៤៣ | ១.២០២.១១៥ | ៥.២១៥.០៣១ | ១.២៨៦.៧០៩ |

### ក. ប្រាក់តម្កល់ដើមទុនតាមច្បាប់

ក្នុងការអនុលោមតាមប្រកាសលេខ ធ៧-០៧-១៦៣ប្រ.ក. ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០០៧ ស្តីពីការផ្តល់អាជ្ញាប័ណ្ណទទួល ប្រាក់បញ្ញើពីសាធារណជន របស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ក្រុមហ៊ុនត្រូវបានតម្រូវអោយរក្សាប្រាក់តម្កល់ដើមទុនតាមច្បាប់ នៅធនាគារកណ្តាលចំនួន ១០% នៃដើមទុនចុះបញ្ជី។ ប្រាក់តម្កល់នេះ នឹងត្រូវបង្វិល អោយក្រុមហ៊ុនវិញនៅពេលដែល ក្រុមហ៊ុនស្ម័គ្រចិត្តបញ្ចប់អាជីវកម្មរបស់ខ្លួន ហើយមិនមានបំណុលលើ ប្រាក់បញ្ញើរបស់អតិថិជន។

### ខ. ប្រាក់បញ្ញើបម្រុង

ក្នុងការអនុលោមតាមប្រកាសលេខ ធ៧-០៧-១៦៣ប្រ.ក. ស្តីពីការផ្តល់អាជ្ញាប័ណ្ណទទួលប្រាក់បញ្ញើពីសាធារណជនរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាក់បញ្ញើបម្រុង គឺជាប្រាក់បញ្ញើបម្រុងអប្បបរមា ដែលត្រូវបានគណនាតាមអត្រា៨% នៃប្រាក់បញ្ញើរបស់អតិថិជនសរុប។

### គ. អត្រាការប្រាក់

ប្រាក់បញ្ញើបម្រុង និងគណនីចរន្ត មិនមានការប្រាក់ទេ។ ប្រាក់តម្កល់ដើមទុនតាមច្បាប់ ជាប្រាក់រៀល ទទួលបានការប្រាក់ ៣%ប្រចាំឆ្នាំ។ ការទូទាត់ការប្រាក់ ត្រូវបានធ្វើឡើងប្រចាំឆមាស។

## ក្រុមហ៊ុន អន្តរ មីក្រូហិរញ្ញវត្ថុ (កម្ពុជា) ខូ អិលធីឌី

## កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ
## សម្រាប់ការិយបរិច្ឆេទដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១១

### ៦. សមតុល្យនៅធនាគារផ្សេងៗ

| | ២០១១ | | ២០១០ | |
|---|---|---|---|---|
| | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក |
| គណនីចរន្ត | ១.១៨២.៩៨២ | ២៩២.៨៩០ | ៧៧៧.២៦៥ | ១៩១.៧៧៥ |
| គណនីសន្សំ | ១៣.៦៤៧.២៦៣ | ៣.៣៧៨.៨៧២ | ៩.០៨៨.៨៣៣ | ២.២៤២.៤៩៥ |
| គណនីប្រាក់បញ្ញើមានកាលកំណត់ | ៥១.២៩៥.៣០០ | ១២.៧០០.០០០ | ២៦.១០២.១០០ | ៦.៤៤០.១៩៣ |
| | ៦៦.១២៥.៥៤៥ | ១៦.៣៧១.៧៦២ | ៣៥.៩៦៨.១៩៨ | ៨.៨៧៤.៤៦៣ |

គណនីចរន្តមិនមានការប្រាក់ទេ។ អត្រាការប្រាក់ប្រចាំឆ្នាំ នៃប្រាក់បញ្ញើផ្សេងៗ ត្រូវបានសង្ខេបដូចខាងក្រោម ៖

| | ២០១១ | ២០១០ |
|---|---|---|
| គណនីប្រាក់បញ្ញើមានកាលកំណត់ | ៥% | ៤,២៥% |
| គណនីសន្សំ | ០,២៥% - ០,៧៥% | ០,១០% - ២% |

រាល់សមតុល្យនៅធនាគារផ្សេងៗ ដែលបានដាក់បញ្ញើនៅធនាគារក្នុងស្រុក និងគ្រឹះស្ថានហិរញ្ញវត្ថុនានា មានដូចខាងក្រោម ៖

| | ២០១១ | | ២០១០ | |
|---|---|---|---|---|
| | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក |
| ធនាគារ Foreign Trade Bank of Cambodia | ៥១.៦៤២.៥៦៨ | ១២.៧៨៥.៩៧៩ | ២៣.៩៧៦.៩៥១ | ៥.៩១៥.៨៥៣ |
| ធនាគារ Acleda Bank Plc | ១៤.០៨៧.១០៥ | ៣.៤៨៧.៧៧១ | ៨.៩១៤.៩២៩ | ២.១៩៩.៥៨៨ |
| ធនាគារ Maruhan Japan Bank Plc | ១៦២.៨៩៨ | ៤០.៣៣១ | - | - |
| ក្រុមហ៊ុន Wing Cambodia LTD | ១៣៣.៩០៥ | ៣៣.១៩៣ | ៣.០៣០.៩៩៣ | ៧៤៧.៨៣៩ |
| ធនាគារ ANZ Royal Bank | ៩៩.០៦៩ | ២៤.៥២៨ | ៤៥.៣២៥ | ១១.១៨៣ |
| | ៦៦.១២៥.៥៤៥ | ១៦.៣៧១.៧៦២ | ៣៥.៩៦៨.១៩៨ | ៨.៨៧៤.៤៦៣ |

## ៧. ឥណទានអតិថិជន

| | ២០១១ | | ២០១០ | |
|---|---|---|---|---|
| | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក |
| ឥណទានធនាគារភូមិ : | | | | |
| សងនៅចុងវគ្គ | ៧៩.០៨៦.៤៨៦ | ១៩.៥៨០.៧១០ | ៦០.៧១៦.១៣៤ | ១៤.៩៨០.៥៤១ |
| សងបណ្តាក់ | ៤៩.០៤៦.៧៥២ | ១២.១៤៣.២៩១ | ២២.៨៥៤.៣២២ | ៥.៦៣៨.៨៦៦ |
| សងរំលោះដើមថេរ | ២៩.៤៤៧.៥៦៨ | ៧.២៩០.៨០៧ | ២៤.៨៣៨.៥០៧ | ៦.១២៨.៤២៥ |
| ឥណទានឯកត្តជន : | | | | |
| សងរំលោះដើមថេរ | ២០.២៨១.៨០៨ | ៥.០២១.៤៩២ | ១៧.៨២០.៥០៦ | ៤.៣៩៦.៨៦៨ |
